# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែកញ្ញា លេខ ៩

ព. ស. ២៤៩៤ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានឹងគ្រឹស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីគួត់) (តមក)... | លោកវ៉ាយ-ប៊ុក .......... | ៦៤៣ |
| ពន្លឺអាស៊ីទ្វីប (តមក)........... | លោកវ៉ាយ-ប៊ុក .......... | ៦៤៧ |
| វិនយកថា.................... | ព្រះបាឡាត់អរិយកស្សបតុង—ឈួន | ៦៥៣ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ការបណ្តុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម .... | ៦៥៩ |
| អីទ្បេណា-សិម្ប៉ាណា (តចប់)..... | លោកផេង-ជ្រីវ........... | ៦៧០ |
| រឿងសាមកុក (តមក)........... | ឧកញ៉ា ទួ-កន.......... | ៦៧៨ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. | ឧកញ៉ា ឈឹម-ក្រសេម ..... | ៦៩៣ |
| រឿងអារក្សថ្លែងរឿងម្តេប្រាំ (តមក).... | លោកសាង-សាវ៉ាត ....... | ៧០០ |
| **កំណត់ទីងប្រវត្តិការណ៍** | | |
| ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត គុណបាលបិយសេន ម៉ាល៉ាល៉ះសេកេរះ (តមក) | ពុទ្ធសាសនបណ្ឌិត្យ......... | ៧១០ |


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៤៥ រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES


| PARTIE RELIGIEUSE | | Pages |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite) | M. RAY-BUC | 643 |
| La Lumière de l'Asie (suite) | M. RAY-BUC | 647 |
| Vinayakatha | Vén. KONG-CHHUON | 653 |
| **PARTIE LITTERAIRE** | | |
| Education morale (suite) | Vén. PENG-PAM | 659 |
| Histoire d'Hélèna-Simiana (suite) | M. PHENG-CHRIEU | 670 |
| Histoire de SAMKOK (suite) | Oknha NOU-KAN | 678 |
| Histoire du Royaume du Cambodge (suite) | Oknha CHHIM-KRASEM | 693 |
| Les vingt-cinq récits du mauvais génie (suite) | M. SANG-SAVATH | 700 |
| **NOTES ET CHRONIQUES** | | |
| Voyage au Cambodge du Dr. G.P. Malalasekera, Président du Centre mondial des Bouddhistes de Ceylan (suite) | Institut Bouddhique | 710 |


Prix d'abonnement annuel comprenant 12 numéros: 145$00

# ពុទ្ធសាសនា និង គ្រិស្តសាសនា

## សន្និសិទលោកបណ្ឌិត មីគូត៍

លោក ពៃយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្ដី "ហ្វ្រង់អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

---

សង្គ្រាមខាងសាសនាគឺជាភេសកភាព ដែលផ្សាយចេញពីមនោសញ្ចេតនាដែលជ្រួតជ្រាបទៅក្នុងស៊ីវិល្បខាងបស្ចិមប្រទេស ដែលកើតឡើងដោយគ្មានការសន្ដោសគ្នាទៅវិញទៅមក ៗ គតិពួកបច្ចិមជាតិមាននិស្ស័យបែបនេះ គឺថាបើអនុម័តិនូវមតិនយោបាយ ឬសាសនាណាមួយ ពួកនេះទុកមតិដែលខ្លួនយល់ថាជាធម៌សច្ចៈយ៉ាងខ្ពង់ខ្ពស់ ចំណែកមតិឯទៀតមានសភាពខុស មានន័យផ្សេងទាំងអស់ ៗ វត្តដែលលំបាកជាងគេ គឺពួកនេះយល់ថា ការដែលកំហែងបង្ខំដោយប្រើវិចារណញ្ញាណឲ្យអ្នកឯទៀតយល់ដូចខ្លួន ជាការប្រសើរ, ហើយបើការប្រើបែបនេះមិនសម្រេចទៅតាមបំណង ត្រូវការប្រើពលភាពតទៅទៀត ៗ កិច្ចដែលត្រូវការខានមិនបាន ដោយប្រាថ្នាឲ្យអ្នកដទៃបានសេចក្ដីសុខ ដោយអ្នកដទៃនោះមិនព្រមយល់តាម ឬការបង្ខំឲ្យអ្នកដទៃទទួលប្រតិបត្តិតាមយោបល់របស់ខ្លួនចំពោះស៊ីវិល្ប (អារ្យធម៌) ចំពោះជីវភាពក្នុងសង្គម, សាសនានេះជាមូលដ្ឋាននាំឲ្យកើតនូវសង្គ្រាមស៊ីវិលនឹងសង្គ្រាមសាសនា

ក្នុងលោក ឬសង្គ្រាមរវាងប្រជាជាតិ ជាបុព្វហេតុនៃគតិអាណានិគមនិយម បណ្តាលឲ្យកើតសង្គ្រាមសេដ្ឋកិច្ចនឹងបេសកកម្ម ។

ចំណែកខាងបូព៌ាប្រទេស មិនដែលស្គាល់នូវរឿងរ៉ាវដ៏លាមកបែបនេះទេ ។ ប្រជាជននៃទ្វីបអាស៊ីមានស៊ីវិល័យដោយឡែកពីគ្នា មានប្រពៃណីទំនៀមទម្លាប់សាសនាផ្សេងៗគ្នាដែលពួកនេះបានប្រកាន់ខ្ជាប់, តែមិនបានអួតអាងថាសភាពដែលពណ៌នាខាងលើនេះ ជាសច្ចធម៌ប្រកបដោយឯកភាពដូច្នេះឡើយ ។ ពួកនេះតែងយល់ថា គង់មានអ្នកដទៃទៀតមានចិត្តគិតផ្សេងពីខ្លួន ហើយគង់មានយោបល់ប្រកបទៅតាមវិចារណញ្ញាណមិនលែងឡើយ ។ ពួកនេះ តែងមានគំនិតផ្សេងពីគំនិតអ្នកដែលមិនមានការពិចារណាផ្ទុយគ្នា ដូចការពិចារណាទៅតាមការណាការណ៍វិទ្យា (Logique) នៃបណ្ឌិតអារីស្តូត តែវិទ្យានេះមិនបាននាំឲ្យពួកទាំងនោះមានអាកប្បកិរិយាមិនស្របគ្នា ដែលជាបុព្វហេតុនាំឲ្យកើតនូវសង្គ្រាមនឹងសេចក្តីស្អប់គ្នាទៅមកទេ ។ ពួកទាំងនេះ មិនមានអំនួតដើម្បីនឹងកំហែងបង្ខំឲ្យសាកលលោកធ្វើតាមគំនិតខ្លួនឡើយ, ហើយយល់ថា គំនិតបង្ខំប្រើអំណាចហួសប្រមាណនៃពួកបស្ចិមជាតិ ចំពោះរឿងនេះទុកដូចជាអករណីយកិច្ចដែលមកពីការអប់រំអាក្រក់ ។

កាលខ្ញុំអាស្រ័យនៅកោះស៊ីឡង់ ខ្ញុំមានសេចក្តីងឿងឆ្ងល់ពន់ពេកដោយបានឃើញនៅមន្ទីរកុដិនៃចៅអធិការវត្តដែលខ្ញុំអាស្រ័យ មានរូប

ព្រះគ្រិស្តស្ថិតនៅជិតព្រះពុទ្ធរូប ។ លោកចៅអធិការធ្លាប់ចំពោះ
អាកប្បកិរិយាខ្ញុំដែលជឿងធ្ងល់អំពីការប្រព្រឹត្តិបែបនេះ, ហើយលោកបាន
ពោលសរសើរចំពោះព្រះគ្រិស្តនឹងការសក្ការៈនៃព្រះគ្រិស្ត ។ តាំងពីនោះ
មក ខ្ញុំបានឃើញជាញឹកញយថាពួកពុទ្ធមាមកជន មិនប្រកាន់បក្ខពួក
និកាយឡើយ ។ ពួកនេះតែងអប់រំស្មារតីកុំឲ្យវិបរិតហើយសរសើរដោយ
ស្មោះស្ម័គ្រនូវសាសនាដទៃ, ពិនិត្យឲ្យយល់ជាក់ច្បាស់នូវសាសនានោះ
ដោយសមានចិត្ត ។ ប្រាជ្ញាជ្រាលជ្រៅដ៏ធំទូលាយនេះ ច្រើនចៀសវាង
ពីការប្រើបញ្ចុះបញ្ចូលអ្នកឯទៀត ឲ្យមកកាន់សាសនារបស់ខ្លួន; បើមាន
អ្នកណាពេញចិត្តខាងសាសនាដែលពួកនេះកាន់, ពួកនេះតែងមានចិត្ត
សន្តោសព្រមបង្ហាត់បង្ហាញ ឲ្យពួកនោះបានចេះដឹងនូវវិជ្ជាខាងព្រះពុទ្ធ-
សាសនា តែមិនមានបំណងនឹងបញ្ចុះបញ្ចូល ឲ្យមកកាន់សាសនាខ្លួន
ឡើយ ។ ពួកពុទ្ធមាមកជនតែងមានចិត្តគោរពកោតខ្លាច បំពោះចិន្តា
អ្នកដទៃហើយមិនមានគំនិតយល់ថា សាសនាដែលខ្លួនកាន់ជាសាសនា
វិសេសប្រកបដោយសច្ចធម៌ តែមួយឯកឯង, ពួកនេះគិតថាសាសនា
ទាំងអស់តែងទូន្មាននូវធម៌ពិតមែនដូចគ្នាទាំងអស់ តែក្នុងសាសនានីមួយៗ
តែងយកសច្ចធម៌នោះទៅប្រតិស្ឋានជារូបភាព ប្រកបទៅតាមចរិតជាតិ,
ប្រពៃណីគួរជាទីគោរព ។ តើមានប្រយោជន៍អ្វីត្រង់ការប្រែប្រួល
សាសនានោះ ព្រោះសាសនាទាំងអស់មានវត្ថុបំណងដូចគ្នាទាំងអស់

សាសនាមានអត្តរសតែមួយ តែផ្លូវដែលទៅកាន់ទីនោះមានសភាពខុសគ្នាប៉ុណ្ណោះ?

គេអាចជឿដល់ដោយឃើញថា ពួកគ្រិស្តសាសនិកជននឹងពុទ្ធមាមកជនប្រតិបត្តិតាមគោលការណ៍នៃសីលធម៌ដូចគ្នាសោះ តែបែរទៅជាមានអាកប្បកិរិយាខុសគ្នាដោយចំណុចសំខាន់នៃសីលធម៌ គឺអហឹសភាព (កិរិយាមិនបៀតបៀនអ្នកដទៃ) នឹងគតិលទ្ធកម្មដោយអាវុធ esprit de conquête គោរពនៃចិន្តាអ្នកដទៃដែលប្រព្រឹត្តទៅនាំឲ្យកើតផលដ៏លាមក គឺសង្គ្រាម ។ ខ្ញុំយល់ថាគំនិតខុសគ្នានេះមានហេតុដ៏សំខាន់គឺចំណុចមួយដ៏ធំខាងលទ្ធិពុទ្ធសាសនា ដែលខ្ញុំមានបំណងដំរាបលោក-អ្នកទាំងអស់គ្នាក្នុងពេលនេះ គឺលទ្ធិអនត្តា (មិនមែនរបស់ខ្លួន non-égo) ។

ព្រះពុទ្ធសាសនាទូន្មានថា វត្ថុទាំងឡាយ, សត្វលោកទាំងអស់ដែលនៅជុំវិញយើង គឺមិនមែនជាជីវសត្វស្ថិរវត្តប្រកបដោយនិច្ចភាពទេ តែមានសមាសភាពជាសំណុំធាតុ មានធាតុប្រមូលប្រស័យទាក់ទងគ្នាចេញចូលជានិរន្តរកាល ។ (មា

សូមរាំងខ្លួនដោយសុភាសិតនេះ

ហាត់នឿយពេក កុំដេកបួល

ដំណោក កុំនិយាយនឹងស្រី

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៣

La Lumière de l'Asie

## លោកស៊ឺរ-អេតវាំងអារណូលត៍ តែង

*លោក ពយ-ប៊ុក ក្រមការប្រែរៀបរៀង*

(តទៅ)

---

ក្នុងពេលនោះ ព្រះនាងយសោធរាទ្រង់ព្រះសណ្ដាប់នូវពាក្យខាងលើនេះ ទ្រង់មានព្រះលោហិតស្រោចស្រប់ព្រះភក្ត្រ ដោយព្រះទ័យសោមនស្សពន់ពេក ប្រៀបដូចទឹកស្ទឹងគង្គាហូរខ្លាំងនៅក្នុងគុហាភ្នំ, ពេលទឹកកករលាយជាខ្លាំង, ព្រះនាងទ្រង់តើនឡើងបានទះព្រះហស្តរណ្តំគ្នាហើយទ្រង់សប្បាយព្រះទ័យពន់ពេក ទាល់តែហូរជលនេត្រ ៗ ព្រះនាងទ្រង់មានព្រះបន្ទូលទៅកាន់ស្រីព្រះស្នំថា " ត្រូវនាងចាត់ឲ្យហៅពួកពាណិជមកទីនេះជាប្រញាប់ ត្រង់ម្ខាងវាំងនន (ពុរដាហ៍)(១) ព្រោះត្រចៀកខ្ញុំចង់ក្រេបផឹកនូវដំណឹងដែលពីរោះពិសា ប្រៀបដូចបុគ្គលមានបំពង់កស្ងួតចង់ផឹកទឹកដូច្នោះ, ចូរនាងប្រាប់ពួកពាណិជទាំងនោះឲ្យចូលមកដោយរួសរាន់នៅទីនេះ ហើយប្រាប់ថា បើរឿងដែលខ្លួននិទាននោះពិតដូចនាងឯងពណ៌នាប្រាប់ខ្ញុំៗ នឹងឲ្យអ្នកទាំងនោះនូវមាសនឹងត្បូងផ្សេងៗ

---

១ ទំនៀមនៅប្រទេសឥណ្ឌាខាងជើង ពួកស្ត្រីដែលមានវណ្ណៈខ្ពស់មិនត្រូវបង្ហាញរូបឲ្យជនបរជាតិឃើញទេ បើត្រូវការចរចានឹងពួកទាំងនោះត្រូវឲ្យជនបរទេសឈរឬអង្គុយនៅម្ខាងរនាំងឬវាំងនន ។

ដែលព្រះមហាក្សត្រិយ៍គ្រប់អង្គពេញព្រះរាជហឫទ័យ ចូរនាងទាំងអស់គ្នាកុំភ្លេចមកជាមួយនឹងពួកពាណិជផង ខ្ញុំនឹងឲ្យទេយ្យវត្ថុដល់នាងក្នុងពេលនោះ ដែលជាទេយ្យវត្ថុសំដែងសេចក្ដីអនុគ្រោះរបស់ខ្ញុំ ចំពោះនាងទាំងអស់គ្នា" ។

ពួកពាណិជក៏ទៅកាន់ព្រះរាជដំណាក់របស់ព្រះនាង ដោយដំហានរង្លើលៗ តាមវិថីក្នុងព្រះបរមរាជវាំង បានជួបប្រទះនឹងពួកស្រីស្នំជាច្រើននាក់ដែលឈរមើលមកដោយស្ងៀមស្ងាត់ ។ ពួកពាណិជបានលាន់មាត់សរសើរព្រះបរមរាជវាំងដែលមានប្រាសាទសន្ធោសន្ធៅអស្ចារ្យ ។ លុះពួកពាណិជទៅដល់ក្រោយវាំងនោះ បានឮសូរសៀងស្ត្រីមានសភាពទន់ផ្អែមល្ហែម, មិនសូវច្បាស់, ញ័រតែពីរោះពន់ពេកថា: "ឱអ្នកដំណើរទាំងឡាយ! អ្នកទាំងអស់គ្នា បានអញ្ជើញមកពីស្រុកឆ្ងាយ, ឮថាអ្នកបានឃើញព្រះរាជស្វាមីខ្ញុំ ហើយបានក្រាបថ្វាយបង្គំ ឮថាព្រះអង្គទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទ្រង់ជាសាស្ដាចារ្យនៃទេវតានឹងមនុស្សទាំងឡាយ, ជាសទ្ធបុគ្គល ជានិយ្យានិកបុរសដែលជួយស្រោចស្រង់មនុស្សពិភពលោកឲ្យផុតចាកទុក្ខលំបាក ហើយព្រះអង្គទ្រង់គង់នៅទីនោះ, ចូរអ្នកប្រាប់ខ្ញុំ បើពិតជាអ្នកទាំងអស់បានជួបនឹងព្រះអង្គមែន អ្នកឯងជាទីរាប់អាននៃខ្ញុំ ខ្ញុំគួរទទួលអ្នកទាំងអស់ដោយសេចក្ដីរាក់ទាក់ផង ដោយចិត្តស្មោះស្ម័គ្រផង" ។

ត្របុស្សៈទូលព្រះនាងថា "សូមក្រាបបង្គំព្រះនាង, ទូលព្រះបង្គំទាំងអស់បានឃើញព្រះបរមគ្រូជាទីគោរពមែន ! ទូលបង្គំទាំងអស់គ្នាបានថ្វាយបង្គំព្រះអង្គ ព្រោះថាព្រះអង្គដែលពីដើមជាព្រះអង្គម្ចាស់ ឥឡូវទ្រង់បានកិត្តិនាមខ្ពង់ខ្ពស់ជាងព្រះមហាក្សត្រិយ៍ទៅទៀត ។ ព្រះអង្គទ្រង់បានសម្រេចនូវសម្មាសម្ពោធិញ្ញាណ នៅក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរខាងមាត់ស្ទឹងផល្គុ ហើយទ្រង់អាចប្រោសស្រង់សត្វលោកដោយព្រះអង្គឯង ទ្រង់ជាមហាមិត្តចំពោះសត្វនិករ ហើយទ្រង់ជាសាស្តាចារ្យនៃមនុស្សទាំងអស់ក្នុងលោក ព្រះអង្គទ្រង់ជាមហាបុរស ទ្រង់បានធ្វើទុក្ករកិរិយាដោយលំបាកពន់ពេក ទ្រង់បានទតយល់ពន្លឺដោយព្រះប្រាជ្ញាញាណ ទ្រង់បានព្រះរាជទានឱវាទទុកឲ្យសត្វប្រតិបត្តិតាម ។ សូមព្រះនាងទ្រង់ជ្រាបថា ព្រះរាជស្វាមីព្រះនាងទ្រង់ប្រកបដោយសុខភាព ដូចបុគ្គលដ៏ប្រសើរស្ថិតនៅពីលើទុក្ខទាំងពួង ព្រះអង្គជាព្រះអាទិទេពអាចធ្វើឲ្យសាបសូន្យនូវទុក្ខនៃមនុស្សលោក, ព្រះអង្គប្រកបដោយឆព្វណ្ណរង្សីផ្សាយចេញពីអរិយសច្ចៈដែលទ្រង់បានជ្រាបច្បាស់, ទ្រង់មានឆវីវណ្ណភ្លឺចាំងចែងដូចមាស ។ បើព្រះអង្គទ្រង់ត្រាច់ពីទីក្រុងមួយទៅទីក្រុងមួយ ទ្រង់បានទេសនាពន្យល់សព្វសត្វអំពីមធ្យោបាយផ្សេងៗ ដឹកនាំសត្វទៅកាន់សន្តិសុខ, ចិត្តរបស់មនុស្សទាំងអស់ត្រាច់ទៅតាមក្រោយព្រះអង្គដូចជាស្លឹកឈើប្រមូលទៅតាមអំណាចព្រះពាយបោកបក់ ឬដូចជាបសុសត្វដើរតាម

មេហ្វូងដែលស្គាល់វាលស្មៅ ។ ទូលព្រះបង្គំទាំងអស់គ្នាបានស្ដាប់ដោយគោរពនូវព្រះឱស្ឋព្រះអង្គពីរោះពិសាអស្ចារ្យ ឯគយាក្នុងឧទ្យានជិរនិកៈ (Tchîranika), ព្រះអង្គទ្រង់យាងមកកាន់ទីនេះមុនរដូវភ្លៀងជាដំបូង” ។

ត្របុស្សៈក្រាបទូលព្រះនាងយសោធររួចហើយ, ព្រះនាងទ្រង់មានព្រះទ័យសោមនស្សជាខ្លាំង ហើយទ្រង់មិនអាចតបឆ្លើយទៅពាណិជវិញរួចៈ “សូមអ្នកនៅសុខជានិរន្តរកាលក្នុងទីនេះចុះ, ឱអ្នក! អ្នកដែលបានឲ្យដំណឹងពីរោះដល់ខ្ញុំៗ អរណាស់, ចុះអ្នកបានដឹងនូវទុក្ករកិច្ចរបស់ព្រះអង្គយ៉ាងណាខ្លះ? ។”

រួចពីនោះមក, កល្លកៈបានក្រាបទូលព្រះនាងតាមដែលខ្លួនបានដឹងពីពួកដែលនៅជ្រោះភ្នំ, គឺទូលអំពីព្រះអង្គទ្រង់តស៊ូនឹងកងទ័ពមារព្រមទាំងសេនាមារក្នុងវេលាយប់ដែលអាកាសងងឹតពាសពេញមេឃា, ផែនដីញាប់ញ័រជាខ្លាំង ហើយរលកទឹកក្នុងស្ទឹងគង្គាបោកបក់រំជួលសម្បើមដោយសេចក្ដីក្រោធនៃមារាធិរាជនោះ ។ កល្លកៈនោះក្រាបទូលព្រះនាងតទៅទៀតអំពីព្រះប្រាជ្ញាញាណ ដែលប្រៀបដូចជាបុព្វណ្ហសម័យដ៏ប្រកបដោយរស្មីភ្លឺចាំងចែងអស្ចារ្យ ចេញពីខ្វាងមេឃធ្វើឲ្យកើតសេចក្ដីសង្ឃឹមចំពោះមនុស្សក្នុងសាកលលោក ព្រមទាំងបានឃើញព្រះសម្មាសម្ពុទ្ធជាបរមគ្រូគង់នៅក្រោមដើមអជបាលនិគ្រោធ ទ្រង់ក្រេបនូវវិមុត្តិសុខនៃសម្មាសម្ពោធិញ្ញាណ ។ តែព្រះអង្គទ្រង់គង់ស្ងៀមជាច្រើនថ្ងៃ

ពិចារណានូវពុទ្ធកិច្ចត្រង់ការស្រោចស្រង់សត្វឲ្យផុតចាកទុក្ខ ដែលស្ថិតនៅក្នុងព្រះរាជហឫទ័យព្រះអង្គដូចជាមាសមួយដុំ ព្រោះព្រះអង្គចង់បង្ហាញផ្លូវសត្វឲ្យប្រាសចាកសេចក្ដីសង្ស័យ ដើម្បីនឹងដឹកនាំសត្វទៅកាន់មាត់ស្ទឹងអរិយសច្ច ព្រោះព្រះអង្គទ្រង់ព្រះតម្រិះថា ធ្វើម្ដេចហ្ន៎ឲ្យមនុស្សទាំងអស់ដែលធ្លាប់ពេញចិត្តខាងការប្រព្រឹត្តបាបអកុសល ដែលធ្លាប់ជាប់ចំពាក់នឹងកាមារម្មណ៍ផ្សេងៗ ដែលធ្លាប់ក្រេបនូវឱជារសភាន់ច្រឡំនៃប្រកពមួយពាន់កន្លង ដែលធ្លាប់គ្មានប្រាជ្ញា ឬគ្មានថាមពលអាចបំបាក់នូវបំណងខុសបាន, ធ្វើម្ដេចឲ្យសត្វយល់នូវធម៌និទានៈ ១២ យ៉ាង (១) នឹងវិន័យដែលស្រោចស្រង់សត្វដែលជាប់ក្នុងវដ្ដសង្សារ នាំឲ្យមនុស្សលោកភ័យខ្លាច ដូចជាបក្សាទៅក្នុងទ្រុងចាកចេញពីទ្វារទ្រុងបើកចំហបាន? ព្រោះហេតុដូចនេះ យើងមិនអាចទទួលផលល្អអំពីជោគជ័យនោះទេ បើនៅលើផែនដីនេះគ្មានអ្វីជាសរណៈទីពឹង ៗ ព្រះពុទ្ធដែលទ្រង់បាន

---

១ និទានៈ ១២ នោះគឺឡាក់កោលនៃជីវភាពដែលមានបច្ច័យទាក់ទងគ្នាដោយហេតុផលបានដល់ការដែលឃើញជាសំខាន់គឺទុក្ខជាប់ជិតជាមតាមបុគ្គល, ហេតុនៃទុក្ខគឺការកើត, ហេតុនាំឲ្យកើតមកពីជាតិ, ហេតុដែលកើតជាតិគឺតណ្ហាៗ មកពីវេទនាៗ មកពីផស្សៈៗ មកពីសឡាយតនៈៗ មកពីនាមរូបៗ មកពីវិញ្ញាណៗ មកពីសង្ខារៗ មកពីអវិជ្ជា ។ ព្រោះហេតុដូចនេះត្រូវបំបាត់អវិជ្ជា ទើបបានដល់ផ្លូវសុខ ។ (គម្ពីរខ្លះថា បដិច្ចសមុប្បាទឬបច្ចយាការ) ។ បើតាមធម៌បដិច្ចសមុប្បាទក្នុងគម្ពីរអភិធម្មសង្គហៈ គឺ ជរាមរណៈជាបច្ច័យឲ្យកើតជាតិ ៗ នាំឲ្យកើតភពៗ ឧបាទានៗ តណ្ហាៗ វេទនាៗ ផស្សៈៗ សឡាយតនៈៗ នាមរូបៗ វិញ្ញាណៗ សំខារៗ នាំឲ្យកើតអវិជ្ជា ។

រកឃើញនូវមគ្គសច្ច យល់ឃើញថានេះជាមគ្គសច្ច, ចំពោះជនជាតិសាម័ញ្ញលំបាកនឹងដើរពន់ពេក ហើយទ្រង់ត្រាច់តែមួយព្រះអង្គឯង គ្មានបុគ្គលណាដើរតាមពីក្រោយព្រះអង្គ ។ បានជាព្រះសម្មាសម្ពុទ្ធជាសាស្ដាចារ្យរបស់យើង ដោយព្រះអង្គមានព្រះទ័យករុណាដល់សព្វសត្វ ទ្រង់ព្រះតម្រិះជាមុនសិន, តែក្នុងពេលនោះមានសំឡេងមួយស្រែកពីលើអាកាសឮសព្ទសូរជាខ្លាំង ប្រៀបដូចជាស្ត្រីស្រែកក្នុងពេលដែលប្រសូតបុត្រ ប្រៀបដូចជានាងគង្ហីងព្រះធរណីថ្ងូរថា: "ប្រាកដហើយ, ខ្ញុំនឹងសត្វលោកទាំងអស់មុខជាសាបសូន្យមិនខាន" ។ រួចដល់ស្ងៀមមួយស្របក់, ស្រាប់តែព្រះពាយខាងទិសបស្ចិមពោលដោយសេចក្ដីអង្វរថា: "ឱព្រះទសពលញ្ញាណ! សូមព្រះអង្គសំដែងធម៌ប្រោសសត្វផង" ។ ព្រោះហេតុដូចនេះព្រះបរមគ្រូទ្រង់ទតទៅកាន់សព្វសត្វ, រួចទ្រង់បានជ្រាបច្បាស់ថា មានសត្វខ្លះមានឧបនិស្ស័យចាស់ក្លា មានសត្វខ្លះឧបនិស្ស័យនៅអន់ទន់ខ្សោយ ត្រូវចាំពេលទៅថ្ងៃក្រោយ ដូចជាព្រះសុរិយាកំពុងក្តៅខ្លាំង បោលរស្មីទៅកាន់ទឹកស្រះដែលមានបទុមដុះពាសពេញដឹងច្បាស់ថាបុប្ផាបទុមណាបម្រុងនឹងរីកដោយរស្មីនេះ ឬថាបុប្ផាបទុមណាមិនទាន់ពន្លកចេញពីដើមផង ។ ព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះទ័យសោមនស្សពន់ពេក ទ្រង់លាន់ព្រះឱស្ឋថា: "តថាគតនឹងទៅទេសនាប្រោសសត្វចំពោះអ្នកណាដែលចំផ្ទៀងត្រចៀកស្ដាប់ ឬព្យាយាមរៀនធម៌" ។

(មានត)

# វិនយកថា

ព្រះបាឡាត់អរិយកស្សបៈ ឝុង-ឈ្មួង វត្តបទុមវតី ក្រុងភ្នំពេញ

ទេសនាជាកវិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា

កាលពីថ្ងៃ ១៥ កើតខែកត្តិក ឆ្នាំកុរនព្វសក ព. ស. ២៤៩០ (២៧ - ១១ - ៤៧)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ, អាត្មាភាព ត្រូវវេនសំដែងវិទ្យុធម្មទេសនាចែកជូនអស់លោក-អ្នកសប្បុរសទាំងឡាយស្ដាប់ ។

អាត្មាភាពនឹងសំដែងអំពីវិនយកថា ពណ៌នាអំពីច្បាប់ ។

សួរថា: អ្វីដែលហៅថា វិន័យ? ឆ្លើយថា: ច្បាប់ដែលអ្នកប្រាជ្ញតែងតាំងឡើង ទុកសម្រាប់ប្រដៅមនុស្សទូទៅ ឲ្យមានសណ្ដាប់ធ្នាប់ល្អជាបែបផែនតែមួយ ហៅថា វិន័យ; ការនាំចេញនូវទោសកំហុសផ្សេងៗ ក៏ហៅថា វិន័យ ដែរ ។

វិន័យនេះ យើងត្រូវសិក្សាសូត្ររៀនឲ្យចេះចាំស្ទាត់គ្រប់រយៈមាត្រា, បើចេះចាំហើយត្រូវមានសញ្ញាការកត់សំគាល់ថ្នាក់ជាន់ឲ្យស្គាល់ប្រាកដ ។ បើស្គាល់មុះមុតហើយ ទើបអាចទូន្មានពត់កាយ-វាចាដរាបដល់ចិត្តឲ្យមានរបៀបរាបសារម្យទម្យល្អទៅបាន ពុំប្រឡើសបើស ពុំធ្លាំធ្លងខុសកាលៈទេសៈ ។ ព្រោះថា មនុស្សក្នុងសកលលោកមិនថាស្ត្រី-បុរស គេហស្ថបព្វជិតទេ សុទ្ធតែប្រាថ្នាសេចក្ដីល្អ សេចក្ដី

សុខ សេចក្ដីចំរើនគ្រប់ៗរូប ។ ឯគុណគឺសេចក្ដីល្អទាំងនោះ ពុំមែនកើតឡើងឯងៗតែម្ដងទេ; លុះតែមនុស្សណាកសាងសន្សំប្រតិបត្តិតាមវិន័យ ទើបគុណគឺសេចក្ដីល្អទាំងនោះកើតមានដល់អ្នកនោះ ។ ការដែលគេយើងទាំងអស់គ្នានឹងប្រតិបត្តិវិន័យនោះ ត្រូវចេះត្រូវស្គាល់វិន័យជាមុនសិន ទើបប្រតិបត្តិបានស្រួល ។

ដូចក្រុមគ្រួសារឬវង្សត្រកូលនីមួយៗ ដែលនឹងមានបុគ្គលមារយាទសណ្ដាប់ធ្នាប់ល្អ ចរិយាល្អ ពុំប្រឡោងខាមនោះ ក៏ព្រោះតែក្រុមគ្រួសារវង្សត្រកូលនោះមានវិន័យ គឺគេចេះចាំស្គាល់ច្បាស់ហើយគោរពប្រតិបត្តិថែមទៀត ទើបគេបានទទួលផលគឺសេចក្ដីល្អទាំងនោះ ។ តែបើចេះចាំស្គាល់ហើយ ៗ ពុំព្រមបង្អោនខ្លួនគោរពវិន័យយកមកជាខប្រតិបត្តិទេ នោះក៏ពុំអាចនឹងរកសេចក្ដីល្អ ឬដួបប្រទះនឹងសុន្ទរចរិយាបានឡើយ ។

វិន័យដែលថានាំចេញនូវទោសកំហុសផ្សេងៗនោះ បានដល់ទោសគឺកំហុសដែលនឹងកើតមានឡើង ព្រោះវតិសកាយ-វាចានឹងការគំនិត ។ ចុះបើយើងព្រមសុខចិត្តបង្អោនវិន័យយកមកប្រតិបត្តិ ឲ្យត្រូវតាមរយៈមាត្រានឹងថ្នាក់ជាន់សព្វគ្រប់ហើយ គេទោសសេចក្ដីខុសនឹងកើតឡើងតាមផ្លូវណាបាន ។ ហេតុនេះបានជាពោលថា វិន័យនាំចេញនូវទោសកំហុសផ្សេងៗ ។

វិន័យតាមផ្លូវពុទ្ធសាសនា ព្រះសម្ពុទ្ធទ្រង់ប្រដៅជាសាធារណៈទូទៅពុំមានល័ក្ខខ័ណ្ឌទេ, ទុកជាមនុស្សថ្នាក់ណាជាន់ណាឬសាសន៍ណា

ជាតិណាក៏ដោយ បេះតែបង្អោនមកជាខវត្តប្រតិបត្តិបាន ធ្វើខ្លួនឲ្យបាន ទទួលសន្តិសុខដូចៗគ្នា ។

វិន័យចំណែកខាងអាណាចក្រវិញ ដែលលោកតែងតាំងឡើងត្រូវមានលក្ខណ; ព្រោះមនុស្សបែងទៅជា ៤ វណ្ណៈ គឺៈ ក្សត្រិយ៍, ព្រាហ្មណ៍, វេស្សៈ, សុទ្រៈ ។

ក្សត្រិយ៍នឹងព្រាហ្មណ៍រាប់ថាជាត្រកូលខ្ពង់ខ្ពស់; វេស្សៈ នឹងសុទ្រៈ រាប់ថាជាត្រកូលថោកថយចុះមកទៀត តែវេស្សៈគង់នៅគ្រាន់បើជាងសុទ្រៈ ។ សូម្បីដូច្នោះ វណ្ណៈទាំង ៤ នេះក៏ត្រូវប្រតិបត្តិវិន័យដូចគ្នាដែរ, តែគេគង់គោរពរាប់អានលើកតំកើងខត្តិយត្រកូលជាទីបំផុត ព្រោះគេទុកជាតំណាងជាតិនឹងប្រមុខនៃជាតិរបស់គេ ។

ម្យ៉ាងទៀត វិន័យតាមផ្លូវអាណាចក្រ គេតែងតាំងឡើងពុំសាធារណៈទូទៅដល់រដ្ឋដទៃៗឡើយ គឺជាច្បាប់សម្រាប់ដែនរបស់គេៗប៉ុណ្ណោះ, ពួកមនុស្សទាំងអស់ ក្នុងរដ្ឋមណ្ឌលនោះៗ ត្រូវតែនាំគ្នាប្រតិបត្តិតាម ទើបដំណើរទៅតាមផ្លូវល្អ ទាំងគេចវៀះឲ្យផុតអំពីទោសសេចក្តីខុសទៅបាន ។

សេចក្តីល្អបំផុត គឺពួកមនុស្សទាំងអស់ក្នុងរដ្ឋមណ្ឌលនោះៗ ព្រមសុខចិត្តដាក់ខ្លួនឲ្យតាំងនៅក្រោមវិន័យ ដែលតែងតាំងឡើងជាច្បាប់សម្រាប់រដ្ឋនោះៗ ។

ការដែលយើងនឹងប្រគល់ខ្លួនឲ្យតាំងនៅក្រោមវិន័យ ស៊ប់ស្ងួនបាន នោះ លុះតែខំបណ្តុះនូវហិរោត្តប្បធម៌ ឲ្យលូតលាស់ចំរើនឡើងក្នុងសន្តាន របស់យើងជាដំនួយផង, ព្រោះហិរោត្តប្បធម៌នេះ លោកពោលថាជាធម៌ គ្រប់គ្រងលោកទាំងមូល ឲ្យដំណើរទៅកាន់អារ្យធម៌និងវឌ្ឍនធម៌បាន ។

ចុះអ្វីដែលហៅថាហិរោត្តប្បធម៌? សេចក្តីខ្មាសនិងសេចក្តីខ្លាចអំពើ អាក្រក់គ្រប់យ៉ាងហៅថាហិរោត្តប្បធម៌ ។ បើពួកមនុស្សទាំងអស់ក្នុង រដ្ឋមណ្ឌលនោះៗ បានបង្កើនធម៌ទាំងពីរនេះ មកផ្ទុកក្នុងខ្លួនសន្តានបាន ហើយ នឹងអាចឧបត្ថម្ភខ្លួនឲ្យតាំងនៅក្រោមវិន័យទៅអនាគតបានវែង ឆ្ងាយ, ហើយនឹងបានជាគតិល្អរបស់បច្ឆាជនតាជន គឺជនដែលកើតខាង ក្រោយតៗមក ។

ក្នុងដែនទីមួយៗ ដែលនឹងដំណើរទៅកាន់អារ្យធម៌បាននោះ លុះ តែអស់លោកជារដ្ឋាភិបាល នឹងជាឥស្សរជន នឹងប្រជានិករព្រមមូលចិត្ត គំនិតគ្នាគោរពប្រតិបត្តិវិន័យដែលតែងតាំងឡើង ដោយមានហិរោត្តប្ប-ធម៌ជារណបផង ។ បើជាពុំព្រមមូលចិត្តគំនិតគ្នាឲ្យរឹងប៉ឹងក្នុងការប្រតិ-បត្តិវិន័យទេ, ដែននោះមុខជានឹងបែរមុខទៅកាន់បលុដ្ឋនធម៌ គឺសេចក្តី អាប់ឱនចុះថយទៅពុំខានឡើយ ។

ហេតុនេះ សូមអស់លោកជាឥស្សរជន ព្រមទាំងប្រជាជនក្នុង ខេមរដ្ឋទាំងមូល សូមជួយណែនាំពន្យល់គ្នាឲ្យចេះគោរពប្រតិបត្តិវិន័យ

ដោយមានហិរិោត្តប្បធម៌ជាជំនួយឲ្យរឹងប៉ឹងគ្រប់ៗ គ្នាឡើង ទើបខេមររដ្ឋយើង នឹងធ្វើដំណើរស្ទុះលឿនដឿនទៅកាន់វឌ្ឍនធម៌បានឆាប់រហ័ស ។

កាលបើអស់លោក-អ្នកមានសមត្ថភាព បានជ្រាបអត្ថរបស់វិន័យច្បាស់លាស់ហើយ ត្រូវពិនិត្យមើលមនុស្សទាំងអស់ក្នុងចំណោមខេមររដ្ឋយើង តើសព្វថ្ងៃនេះ 'សម្បូណ៌អ្នកគោរពប្រតិបត្តិវិន័យ ដោយមានហិរិោត្តប្បធម៌ជាសម្លៀកបំពាក់ហើយឬនៅ ? បើសម្បូណ៌គ្រប់គ្រាន់ហើយ ក៏សូមជួយគាំពាររក្សាឲ្យរឹងរឹតតែមាំមួនឡើង, បើមិនសម្បូណ៌ទេ សូមជួយណែនាំពន្យល់ឲ្យយកចិត្តទុកដាក់ ក្នុងការគោរពប្រតិបត្តិវិន័យឲ្យពេញជំហរគ្រប់ៗ គ្នាឡើង ។

ព្រោះខេមររដ្ឋយើងសម័យនេះ មិនថារូបណាជារូបណាទេ គឺព្រមព្រៀងគ្នាទាំងអស់ មានព្រះរាជាជាប្រមុខ សុខព្រះទ័យ សុខចិត្តបង្អោនករជ្ជកាយទាំងស្រុងឲ្យតាំងនៅក្រោមច្បាប់សម្រាប់ដែន ដោយយល់ថាជាវិន័យសម្រាប់ខេមររដ្ឋ ដែលនឹងប្រដៅមនុស្សឲ្យមានសណ្ដាប់ធ្នាប់ល្អ មានបែបផែនល្អ ។

វិន័យនេះនឹងចេះដឹងឯងក៏ទេដែរ ត្រូវតែប្រឹងរៀនសូត្រទន្ទេញទើបអាចនឹងចេះចាំបាន ។ ហេតុនេះ សូមនរជននឹងនារីភាពព្រមទាំងយុវជននឹងយុវនារីរួមជាតិ ដែលកាន់លទ្ធិពុទ្ធសាសនាដូចគ្នាទាំងឡាយចូរអ្នកស្ទុះក្រោកចាកសេចក្តីខ្ជិលច្រអូស ដែលជាគ្រឿងមន្ទិលសៅហ្មង

ដល់ជាតិរបស់អ្នក ។ ចូរអ្នកខិតខំឧស្សាហ៍ប្រកបកិច្ចរបស់អ្នកឲ្យអស់ពីចិត្ត, ឲ្យពេញកំឡាំងគ្រប់គ្នាឡើងតាំងពីឥឡូវនេះទៅ ដោយសមគ្គភាព និងសាមគ្គីធម៌ ទើបអ្នកនឹងបានដល់នូវសុខចំរើនគ្រប់ប្រការ ។

ក្នុងទីបំផុតនេះ, សូមថ្វាយព្រះពរព្រះរាជសិរីសួស្តីព្រះជន្មសុខគ្រប់ប្រការ ចូរមានដល់សម្តេចព្រះបរមបពិត្រព្រះរាជសម្ភារ ជាឯកអគ្គសាសនូបត្ថម្ភកដ៏ទ្រង់នូវព្រះគុណធម៌មហាប្រសើរកល់យប់ថ្ងៃ និងសូមអស់ពួកប្រជានិករក្នុងខេមររដ្ឋទាំងមូលគ្រប់ភូមិគ្រប់ឋាន ចូរសាមគ្គីព្រមព្រៀងយ៉ាងសុខស្ងប់ ប្រសព្វពរទាំង ៤ ប្រការគ្រប់ទិនទិពកត្រីបុះ ។

សំដែងមកក្នុងវិនយកថា ពោលអំពីច្បាប់សម្រាប់ប្រដៅមនុស្សទាំងគ្រហស្ថបព្វជិតឲ្យមានរបៀបរៀបរយល្អ មានសណ្តាប់ធ្នាប់ល្អ ដោយសង្ខេបប៉ុណ្ណោះ ឯវំ ។

ចប់វិនយកថា

# ការបណ្ដុះនិស្ស័យ

## ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

## ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

វាចាសុភាព.— វាចាជាគ្រឿងនាំឲ្យដឹងដល់បំណងគ្នាបាន, បើមិនមានវាចាពាក្យសំដីទេ សូម្បីមានសេចក្ដីចេះដឹង សេចក្ដីចូលចិត្តយ៉ាងណា ក៏មិនអាចនឹងផ្តល់ឬឲ្យសេចក្ដីចេះដឹង សេចក្ដីចូលចិត្តនោះដល់គ្នាបានឡើយ ។ ព្រោះវាចាជាទីតាំងនៃវត្ថុទាំងពួង, វត្ថុទាំងពួងរមែងចេញទៅអំពីវាចា ។ សូម្បីយើងអាចស្គាល់វត្ថុទាំងនោះបានក៏ដោយអាស្រ័យវាចាដែរ ទើបគួរចាត់វាចាថាជារបស់មានដំឡៃដ៏ខ្ពង់ខ្ពស់ ។ មើលចុះក្នុងខ្លួនយើងទាំងមូល រមែងមានមាត់ជាវត្ថុសំខាន់, ព្រោះមនុស្សគ្រប់គ្នា តែងត្រូវការស្ដាប់សង្កេតយកពាក្យសំដីក្នុងខណៈដែលយើងនិយាយ ទាំងខាងល្អទាំងខាងអាក្រក់ ដូចក្នុងតួដំរីទាំងអស់ឥតមានអ្វីបានដំឡៃជាងភ្លុកដូច្នោះ ។ ទើបបុរាណពោលថា : "មនុស្សគេយកសំដី ដំរីគេយកភ្លុក" ។

វាចាល្អ បើយើងនិយាយចេញមក សូម្បីតែ ១ ម៉ាត់ក៏មានដំឡៃស្មើនឹងនគរ, អាចធ្វើឲ្យបានផ្ទះ ឲ្យបានស្រុក ឲ្យបាននគរ ឲ្យបាន

ប្រាក់ ឲ្យបានមាស ឬធ្វើមនុស្សដែលទាស់ទែងគ្នា ឲ្យត្រឡប់ជាមិត្តនឹងគ្នាបាន ដូចពាក្យបុរាណថា "និយាយល្អ ជាសីរីចំពោះខ្លួន" ឬ "និយាយល្អ ជាប្រាក់ជាមាស" ។ វាចាអាក្រក់ បើយើងនិយាយចេញមកត្រឹមតែ ១ ម៉ាត់ ក៏នាំឲ្យមានពៀរ នាំឲ្យកើតជាភ័យធំ នាំឲ្យកើតវិវាទទាស់ទែង ឬកើតបលាចលកោលាហលដល់គ្រួសារ ឬនាំឲ្យខូចដល់ស្រុកដល់នគរ ដល់ប្រាក់ ដល់មាសក៏មាន, បូលកង់ទំនងថា "និយាយអាក្រក់ នាំឲ្យអប្រិយបង្អែ" ឬ "និយាយមិនល្អ ត្រូវខូចមាសខូចប្រាក់" ។ បុរាណភាសិតថា 'អណ្ដាតជាអាទិកន្លង បានសុខទុក្ខផង ពីព្រោះអណ្ដាត" ។

វាចាដែលល្អ ដែលត្រូវធម៌ ត្រូវវិន័យ ត្រូវច្បាប់ ត្រូវទំលាប់ មិនមែនដឹកនាំឲ្យប្រើអាជ្ញា មិននាំឲ្យពាប់សន្ដោរ មិននាំឲ្យកើតសេចក្ដីប្រកួតប្រកាន់ មិននាំឲ្យកើតវិវាទ មិនញុះញង់ឲ្យគេឈ្លោះគ្នាទេ គឺជាវាចាដឹកនាំឲ្យអ្នកស្ដាប់ចូលចិត្ត ពេញចិត្ត គាប់ចិត្តតែម្យ៉ាង ។ ព្រោះការនិយាយល្អនោះ មានលំអទាំងខាងដើម ទាំងកណ្ដាល ទាំងខាងចុង, មានការនិយាយជារបៀប មានការនិយាយជាធម៌ មានការនិយាយជាទីគួរស្រឡាញ់ មានការនិយាយពិត មានការនិយាយត្រូវកាលវេលា មានការនិយាយពីរោះផ្អែមល្ហែម មានការនិយាយជាប្រយោជន៍ ទឹង មានការនិយាយដោយចិត្តមេត្តាជាលក្ខណៈ នេះជាវាចា

សុភាព ។ លក្ខណៈនៃវាចាសុភាពទាំងនេះ លោកសង្គ្រោះបូលក្នុង ប្រភេទនៃវចីសុចរិត គឺប្រព្រឹត្តល្អដោយវាចា ៤ ប្រការ បានដល់វាចាពិត ១ វាចាផ្សះផ្សា ១ វាចាពីរោះ ១ វាចាមានប្រយោជន៍ ១ ។

១.— វាចាពិត — សំដៅយកពាក្យពិតដែលមានការស្មោះត្រង់ ទៀងត្រង់ ខ្ជាប់ខ្ជួនជាលក្ខណៈ, មិនមែនជាសំដីវៀចវេរ បញ្ឆោត ឬកុហកកូតករឡើយ ។ អ្នកមានសច្ចវាចាតែងនិយាយពាក្យពិត ដែលប្រកបដោយប្រយោជន៍ វៀរចាកពាក្យកុហកកូតករ ទាំងវៀរដែលមានទោស បូលចិត្តរក្សាវាចាឲ្យពិត ឲ្យខ្ជាប់ខ្ជួន មិនឲ្យប្រែប្រួលទៅជាយ៉ាងដទៃ ។ បើវាចាដែលខ្លួននិយាយទៅយ៉ាងណា ក៏តាំងចិត្តរក្សាឲ្យពិតតាមសំដីយ៉ាងនោះ មិនឲ្យឃ្លៀងឃ្លាត ទាំងមានគំនិតនឹងថ្វីមាត់ ព្រមទាំងសេចក្ដីប្រព្រឹត្តត្រង់តាមគ្នាទាំងអស់ គួរជាទីជឿ ជាទីកាន់យក នៃមនុស្សទាំងពួងបាន ។ បំណែកមនុស្សមិនមានវាចាពិតវិញ រមែងមានគតិអាក្រក់ជាច្រើនយ៉ាង ដូចជានិយាយមិនពិតខ្លះ មិនត្រង់ខ្លះ វៀចវេរខ្លះ មាយាខ្លះ ត្រឡប់ត្រឡិនខ្លះ, និយាយទៅម្យ៉ាង គិតទៅម្យ៉ាង កិរិយាដែលប្រព្រឹត្ត ក៏បែរទៅជាម្យ៉ាងទៀត ជាហេតុឲ្យគេជឿទុកចិត្តឬកាន់យកតាមផងពុំបាន ។ លោកអ្នកមិនត្រូវធ្វើជាមនុស្សដូច្នោះទេ ចូរគោរពបូជាសច្ចវាចាទុកទៅចុះ ។ ព្រោះសេចក្ដីពិត ជាឫសគល់នៃសេចក្ដីល្អ ចូរថែរក្សាឫសដែលបង្កឲ្យកើតសេចក្ដីល្អនោះដោយសេចក្ដីពិត កុំថែរក្សា

ឬសគល់នៃការកុហកកូតករឡើយ ព្រោះការកុហកជាឫសគល់នៃការវៀចវេរ ។

ក្នុងការអប់រំចិត្ត ឬ ចិត្តានុភាព ត្រូវមានសច្ចាជាឧបការៈយ៉ាងសំខាន់បំផុត ។ ព្រោះសច្ចា អាចធ្វើឲ្យមនុស្សចូលចិត្តនិយាយពិត ចូលចិត្តគោរពបូជាសេចក្ដីពិត ជាក់ជាមានមនុស្សកោតក្រែង ស្រឡាញ់ គោរពរាប់អាន ។ អ្នកចូលចិត្តនិយាយមុសាវាទ ឈ្មោះថាអប់រំខ្លួនឲ្យជាមនុស្សមិនក្លាហាន នឹងបង្អន់ចិត្តានុភាពរបស់ខ្លួនឲ្យអន់កំឡាំង អាប់រាសី ។ ក្នុងតំរាចិត្តសាស្ត្របានពោលថា "បើនរណាមិនខ្ជាប់ខ្ជួនក្នុងសំដីរបស់ខ្លួនត្រឹមណា អ្នកនោះប៉ុនគ្មាននឹងព្យាយាមអប់រំខ្លួនឲ្យមានកំឡាំងចិត្តខ្សោយចុះ ឬព្យាយាមអប់រំខ្លួនឲ្យជាមនុស្សចាញ់ខ្លួនឯងត្រឹមនោះ" ។ បើនរណាចាញ់ខ្លួនឯងហើយ អ្នកនោះនឹងត្រូវចាញ់អ្នកដទៃទៀត ថែមទាំងបានឈ្មោះថាជាអ្នកចាញ់មនុស្សក្នុងលោក ចាញ់ជោគវាសនា ចាញ់ហេតុការណ៍ ចាញ់អ្វីៗគ្រប់យ៉ាង តាំងពីលោកនេះរហូតដល់លោកខាងមុខផង ។ បើមនុស្សយើងឈ្នះខ្លួនឯងហើយ ក៏រាប់ថាជាមនុស្សប្រសើរក្រៃលែង ។ ក្នុងសៀវភៅគោបុត្រសៀម បានពោលទោសអ្នកនិយាយកុហកថាអាក្រក់ក្រៃលែងជាងសត្វព្រៃទៅទៀតៗ

មនុស្សវៀចវេរ មិនបេះ អស់កូតករ
កុហកហើយ គយរ ហ៊ានធានា

ព្រោះបំណាច់ ចង់ឈ្នះ ជនពលគ្នា
ចិត្តដូចជា ទេវទត្ត មាត់ទេវតា ។
នរណាក្លាត សរសើរ មនុស្សបែបនេះ
មុខជាបេះ តែស្លាប់ ដោយកំចា
បេះត្រូវជឹង ថាមនុស្ស គ្មានសច្ចា
សត្វព្រៃផ្សេ បានការ ប្រសើរជាង ។

បើលោកអ្នកខូចសច្ចៈហើយ លោកអ្នកក៏នឹងទៅជាមនុស្សស្លាប់មុនស្លាប់ (ស្លាប់កេរ្តិ៍ឈ្មោះ) ។ សូម្បីលោកអ្នកមានជីវិតរស់នៅ ក៏មិនមាននរណាមួយនឹងរាប់អានឬទុកចិត្តលោកអ្នកបាន ។ លុះតែលោកអ្នករក្សាពាក្យពិតឲ្យជានាទីរបស់ខ្លួន នឹង ថែរក្សាសេចក្ដីពិតនោះទុកឲ្យបានខ្ជាប់ខ្ជួនស្មើដោយជីវិត ទើបខ្លួនលោកអ្នកទៅជាទីគួរគោរពរាប់អានទុកចិត្ត នឹង គួរសរសើរនៃពួកជនអស់កាលយូរលង់ ទាំងកេរ្តិ៍ឈ្មោះក៏ល្បីប្រាកដខ្ចរខ្ចាយទៅមិនសាបសូន្យ ។ មនុស្សដែលកើតមកខាងក្រោយ គង់នឹករឭកនឹងពណ៌នាឈ្មោះលោកអ្នកដោយសេចក្ដីគោរពរាប់អាន, លោកអ្នកក៏នឹងបានឈ្មោះថាជាអ្នកមិនស្លាប់ (មិនស្លាប់កេរ្តិ៍ឈ្មោះ) ។ សូមមើលរឿងរាមកេរ្តិ៍ ត្រង់ព្រះរាមនឹងព្រះបាទមាលីវ គង់ជ្រាបបាន ។

រឿងព្រះរាមនោះ មានពួកប្រជានិករ នាំគ្នានិយមរាប់អានថា "ជាកំពូលនៃពួកមនុស្ស" រហូតដល់នាំគ្នាលើកតំកើងថា "ជាព្រះ

នារាយណ៍បែងភាគ" ផង ៗ ព្រោះព្រះរាមរាប់អានសេចក្ដីពិតយ៉ាងខ្លាំងក្លា ជាងប្រាថ្នារាជសម្បត្តិឬសេចក្ដីសុខទៅទៀត ៗ កាលព្រះបាទធតរថជាព្រះរាជបិតាបានផ្ដាំប្ដេជ្ញារឿងពិតយ៉ាងណា ព្រះរាមក៏ខំរក្សាសេចក្ដីពិតនោះឲ្យប្រព្រឹត្តទៅយ៉ាងនោះគ្រប់ប្រការ ៗ លុះព្រះរាជបិតាអស់ព្រះជន្មទៅ សូម្បីព្រះភីរុតនឹងមហេសីទាំង ៣ ព្រះអង្គ ព្រមទាំងអាមាត្យមុខមន្ត្រីក្នុងក្រុងអយុធ្យា នាំគ្នាចេញទៅអញ្ជើញឲ្យស្ដេចត្រឡប់ចូលមកកាន់នគរវិញ ក៏ព្រះរាមមិនព្រមទទួលពាក្យអញ្ជើញនោះឡើយ សុខចិត្តខំទ្រាំក្រលំបាកនៅក្នុងព្រៃដរាបដល់លើសពី ១៤ ឆ្នាំ តាមកំណត់ដែលព្រះរាជបិតាបានត្រាស់សន្យាទុក ៗ សូម្បីព្រះបាទមាលីរាជដែលយើងពោលប្រារព្ធដល់ដោយសេចក្ដីនិយមរាប់អានថា "ជាមនុស្សមានវាចាពិត" នោះក៏ព្រោះព្រះអង្គមានព្រះបន្ទូលតែពាក្យពិតគ្រប់ពេល ៗ ពួកពលរបស់ព្រះអង្គ ទុកជាមិនចាំបាច់កាន់អាវុធ ក៏គង់មានមនុស្សកោតខ្លាច ទាំងពួកយក្សនឹងពួកទេវតាទៀតក៏ខ្លបខ្លាចដែរ ៗ រឿងនេះ សំដែងឲ្យឃើញថា សច្ចវាចាជាតេជះអំណាចរបស់អ្នកដែលទ្រទ្រង់ទុក ជាអាភរណៈដ៏ប្រសើរ ជាសិរីដ៏ថ្លៃថ្លា លើកតំកើងអ្នកដែលនិយាយឲ្យមានពន្លឺរស្មីជាទីគួរគោរព គួររាប់អាន គួរស្រឡាញ់ គួរជឿ គួរស្ដាប់ នៃមនុស្សគ្រប់ជាន់ទូទៅបានឆ្ងាយនឹងយូរអង្វែង ៗ ដូច្នេះបើលោកអ្នកប្រាថ្នានឹងចារឹកកិត្តិគុណរបស់ខ្លួនទុកក្នុងលោក ឲ្យមហាជន

និយមរាប់អានរហូតដល់កល្បាវសាន ត្រូវកុំធ្វើជាមនុស្សមេករឥតខ្មាស មេល្ងង់ខ្លៅ មិនអៀនអន់ឡើយ កុំសំដែងការមិនពិត អួតអាងខ្លួនឲ្យមនុស្សជឿស្តាប់ កុំបង្កើតរឿងមិនពិតឡើងឲ្យគេជឿខុស ឲ្យកាន់យកខុសតាម កុំទំលាយសេចក្តីពិតដែលមានមែន កុំបន្ទំរឿង កុំដៅយកពិតប្រាកដភ្លាមៗ កុំបំផ្លើសរឿងដែលពិតឲ្យច្រើនជាងហេតុ កុំមាក់ងាយគុណការប្រើសំដីលេងសំនួន ទឹង កុំបណ្តោយឲ្យធ្លាប់មាត់ខាងការនិយាយកុហកឡើយ ។ ចូររក្សាសច្ចវាទុកឲ្យខ្ជាប់ខ្ជួន ចូរអប់មាត់ឲ្យក្រអូបដោយការនិយាយតែពាក្យពិត ។ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងទុកមកថា "ពាក្យសច្ចៈមានរសក្រៃលែងជាងរសទាំងឡាយ, ពាក្យសត្យជាវាចាមិនចេះស្លាប់, មនុស្សដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក៏ព្រោះពាក្យសច្ចៈ" ។

ចូរពោលពិត ឲ្យស្និទ្ធ ជានិស្ស័យ
ទោះនៅក្នុង វង់ដៃ នៃសត្រូវ
ដែលកំញើញ ឲ្យពោល យោលខុសផ្លូវ
ក៏ពុំត្រូវ ក្លែងពោល ឲ្យឃ្លាតពិត ។
ទាំងកិច្ចការ តូចធំ សព្វសារពើ
ក៏ត្រូវធ្វើ ឲ្យត្រង់ តាមគំនិត
ទោះយ៉ាងណា ក៏កុំ លះរឿងពិត
ទើបហៅថា បណ្ឌិត ពិតក្នុងលោក ។

២— វាចាផ្សះផ្សា[១].— ជាវិធីចងមិត្តនឹងផ្សារសាមគ្គី[១] ។ មនុស្សនិយាយវាចាផ្សះផ្សា គឺវាចាមិនញុះញង់ រមែងមានមេត្តាករុណាជាភូមិធម៌ប្រចាំចិត្ត ឥតមានសេចក្តីឫស្យា ចំពោះនរណាមួយនៅក្នុងចិត្តឡើយ, ចូលចិត្តនិយាយតែពាក្យដែលភ្ជួរមិត្តនឹងភ្ជាប់សាមគ្គី, នៅក្នុងទីណា ធ្វើខ្លួនឲ្យជាមិត្តរបស់ពួកគណៈក្នុងទីនោះ ចាត់ថាមានខ្លួនជាអណ្តូងកើតនៃសន្តិសុខ និង ឲ្យប្រជុំជនអាស្រ័យបានសន្តិសុខផង ។ ពិតមែន ការចរចារឿងស្រុកទេសពីប្រទេសមួយទៅមួយនោះ ត្រូវមានទូតដែលស្មោះត្រង់ជាអ្នកតំណាងប្រទេសក្នុងការស្តីដណ្តឹង ត្រូវមានចាស់ទុំជាអ្នកចាត់ការ ។ ឯក្នុងការបែងចែកទ្រព្យសម្បត្តិមត៌កក៏ត្រូវមានមនុស្សជាកណ្តាល ជាអ្នកវិនិច្ឆ័យ ។ បើទូតអ្នកចាស់ទុំនឹងមនុស្សជាកណ្តាលនោះជាអ្នកឈ្លាសវៃ ចេះចរចា ចេះចាត់ការ ចេះវិនិច្ឆ័យហើយ, ការសង្គ្រាមរវាងប្រទេស ការបាក់បែកគ្នារវាងប្តីប្រពន្ធ ការទាស់ទែងបែកបាក់រវាងក្រុមញាតិមិត្ត ឬអ្នកធំនឹងអ្នកតូច ក៏មិនអាចនឹងកើតមានឡើងបានឡើយ ។

អ្នកណាឈ្លាសវៃអង់អាច ចេះនិយាយបញ្ចុះបញ្ចូលទឹកចិត្តរបស់ពួកគណៈ ចេះចងមិត្តនឹងភ្ជួរសាមគ្គីទុកដោយកុសលោបាយ មិនធ្វើឲ្យពួកគណៈបែកគ្នា ដោយពាក្យសំដីចាក់រុក សូម្បីបានឮពាក្យដែលនាំឲ្យពួកគណៈកើតទាស់ទែងខ្វែងគំនិតគ្នាក្នុងទីនេះ ក៏មិននាំយកទៅនិយាយ

---

១ ពាក្យ "ផ្សះផ្សា" និង "ផ្សារសាមគ្គី" មតិខ្ញុំថាគួរប្រើឲ្យត្រូវគ្នា ។ យ. អ. ។

ក្នុងទីណាៗទៀត មានតែពោលពាក្យដែលនាំឲ្យកើតសាមគ្គីដល់ពួកគណៈតែម្យ៉ាង អ្នកនោះសូម្បីនៅក្នុងពួកគណៈដែលធំ ដែលចាត់ថាជាប្រទេសជាតិ ក៏គង់បានទទួលការលើកតំកើងឲ្យធ្វើជាធំ ជាទីគោរពកោតរបស់ពួកគណៈក្នុងទីនោះ ៗ ទាំងពួកគណៈនោះសោត ក៏នឹងមានកម្លាំងមាំមួន ប្រកបដោយសន្តិសុខវឌ្ឍនាការ ជាស្ពានតទៅជាយូរអង្វែង ។

បើលោកអ្នក ចង់ឲ្យប្រទេសជាតិចំរើនរុងរឿង នឹង ចង់ឲ្យខ្លួនជាទីគោរពកោតនៃពួកគណៈ ត្រូវប្រយ័ត្នកុំពោលពាក្យស៊កសៀតដែលជាហេតុទំលាយមនុស្សអ្នកនៅរួមគ្នាឲ្យបែកបាក់គ្នា កាត់មេត្រីរបស់គេឲ្យដាច់ នឹង ធ្វើការទាក់ទងរបស់គេឲ្យសាបសូន្យឡើយ កុំដឹកនាំឲ្យគេលិចលង់ កុំបាក់រុកឲ្យគេកើតប្រកួតប្រកាន់ទំនងប្រចិត្តឈឺចិត្តអន់ចិត្តចំពោះគ្នានឹងគ្នា កុំនិយាយខ្សឹបខ្សៀវដាក់ត្រចៀកគេឲ្យគេវង្វេងជឿថាពិតតាមសំដីដែលយើងនិយាយ ៗ

បើលោកអ្នកបានលះវៀរពាក្យ ដែលហាមប្រាមទាំងនេះហើយ ចូរនិយាយផ្សះផ្សាមនុស្សដែលបែកគ្នាឲ្យជាប់គ្នាវិញ, ចូរនិយាយបន្ទោបន្ទន់ចិត្តមនុស្ស ដែលល្អនឹងគ្នា ឬស្និទ្ធស្នាលចំពោះគ្នារួចហើយឲ្យរឹងរឹតតែជិតជិតនឹងគ្នា ដូចមាសរលាយសាចមួយតទៅទៀត, ចូរនិយាយណែនាំមនុស្សដែលល្អនឹងគ្នាឲ្យមានសេចក្តីសាមគ្គីព្រមព្រៀងគ្នា, ចូរ

និយាយអនុគ្រោះមនុស្សដែលមានសាមគ្គីនឹងគ្នាហើយ ឲ្យរឹងរឹតតែស្និទ្ធស្នាលនឹងគ្នាតទៅទៀត, ចូរនិយាយដឹកនាំមនុស្សដែលមិនទាន់ស្គាល់គ្នាឲ្យស្គាល់គ្នា និង ចូរនិយាយណែនាំមនុស្សដែលស្គាល់គ្នាហើយ តែនៅមិនទាន់ស្និទ្ធស្នាលនឹងគ្នា ឲ្យស្រឡាញ់ស្និទ្ធស្នាលនឹងគ្នា ។

សូមកុំភ្លេច! សូមរឭកខ្លួនឯងជានិច្ចថា "មនុស្សនិយាយស៊កសៀត ជាមនុស្សមេបំបែកបំបាក់ មាននិស្ស័យជាអ្នកបំបែរឭក, ចូលទៅទីណា ត្រូវបែកឭកក្នុងទីនោះ, មានមាត់ជាមេរោគ មានមាត់ជាក្របកស្រមាប់ខ្វារដំបៅ, ចូលចិត្តតែនិយាយដើមគេ ដើម្បីនឹងគាស់សេចក្ដីឡើងហើយនិន្ទាថាអាក្រក់, នាំយករឿងអាក្រក់ពីខាងណោះទៅប្រាប់ខាងណោះ យករឿងអាក្រក់ពីខាងណោះមកប្រាប់ខាងណោះ ហើយចាក់រុកឲ្យអ្នកទាំងសងខាងកើតប្រឈ្លោះទាស់ទែងបែកសាមគ្គីគ្នាឡើយ ទើបបានឈ្មោះថាចូលទៅទីណា មានរឿងអាក្រក់ក្នុងទីនោះ" ។

មេរោគមាត់ ជាមេនាំឲ្យមាត់ដំបៅ និង នាំឲ្យក្របកឺមាត់នៅស្ងៀមមិនបាន ត្រូវព្រួសពិសចេញមករឿយៗ ។ គេថាយើងនឹងដេរមាត់ចង់ប្រើបេសត្រឹម១សរសៃក៏ល្មម តែបើដេរមាត់មនុស្សដែលខូចមាត់វិញ សូម្បីបេសច្រើនក្រសាលក៏មិនល្មម ។ លោកអ្នកមិនត្រូវនៅកែវនឹងគេទេ, ដេកពួនសំងំនៅក្នុងប្រកកំពែងតូចៗ ល្អជាងការនៅក្នុងគ្រឹះស្ថានរាជវាំងធំៗ ជាមួយនឹងមនុស្សបែបនោះ ។ យើងគួរប្រយ័ត្នមាត់យើងកុំឲ្យដំបៅបានៗ

ការស្លាប់ ១ ម៉ឺនដង ក៏គង់ប្រសើរជាងការរស់នៅមានដំបៅមាត់ដែរ ។ ព្រោះគេក្តីឈ្លោះ នៅត្រង់មាត់ល្អ ។ បើមាត់ដំបៅហើយ លោកក៏ឈ្លោះថាមានមាត់សម្រាប់សំឡាប់ខ្លួន ដូចខ្យងនឹងអណ្តើក ។

បើលោកអ្នកវៀររបស់ស្នែងគឺពាក្យសើកសៀត ហើយនិយាយតែពាក្យផ្សះផ្សា ពាក្យមិនសើកសៀតញុះញង់ហើយ មាត់របស់លោកអ្នកក៏នឹងទៅជាមាត់ប្រាសចាកពោគ ជាមាត់អនាម័យ ឬមាត់និរភ័យ ។ មាត់អនាម័យនោះ បើនិយាយកន្លែងណា ក៏ធ្វើឲ្យកើតសេចក្តីរីករាយឡើងកន្លែងនោះ ។ ពិតមែន កាលបើលោកអ្នកឲ្យសេចក្តីរីករាយដល់គេហើយ សេចក្តីរីករាយនោះ ក៏នឹងត្រឡប់មកកាន់លោកអ្នកវិញ ។ សូមប្រយ័ត្នអណ្តាតទុកចុះ មនុស្សដែលបរិភោគឆ្អែតហើយ នៅតែមិនឃើញល្អនោះ គឺមនុស្សធ្លាប់ប្រើអណ្តាតតិះដៀលនិន្ទាមនុស្សទាំងពួង ។ បើលោកអ្នកមិនប្រយ័ត្នអណ្តាតរបស់ខ្លួនទេ មិនយូរឡើយ មុខជាអណ្តាតនោះ កាត់បង់ឫសគល់របស់លោកអ្នកពុំខាន ។ (មានត)

មាត់ជាមេរោគផង ជាធិញ្ញឹសជផង

អណ្តាតជាអាទិ៍កន្លង បានសុខទុក្ខផង ពីព្រោះអណ្តាត។

មនុស្សគេយកសំដី ដំរីគេយកភ្លុក ។

### អ៊ីឡ្យេណា - សិម្យ៉ាណា

"រឿងព្រេងប្រទេសរូម៉ានី"

## លោក ផេង-ជ្រឹវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

រៀបរៀង

(តចប់)

---

នាងអ៊ីឡ្យេណា - សិម្យ៉ាណា ក្រាបបង្គំទូលព្រះចៅថា: សូមចាត់ឲ្យមនុស្សរែកយកទឹកដោះមេសេះទាំងឡាយដើម្បីងូត ៗ ប៉ុន្តែគ្មាននរណាអាចចូលជិតមេសេះទាំងនោះបានទេ តែអ្នកណាប្រហែស មុខជាកព្រាយរយះពោះជាមិនខាន ៗ ព្រះចៅឃើញអាការៈមិនស្រួលដូច្នោះ មានព្រះរាជឱង្ការបង្គាប់ឲ្យព្រះអង្គម្ចាស់ហាវហាន ជាអ្នករែកទឹកដោះសេះទៀត ៗ

ព្រះនាងក៏ស្លុតព្រះហឫទ័យដោយឃើញថា "កិច្ចការៈអ្វីយ៉ាងធ្ងន់ៗ សុទ្ធតែធ្លាក់មកលើព្រះនាងទាំងអស់" ហើយព្រះនាងតាំងស្មារតីយ៉ាងមាំ សូមអង្វរព្រះជាម្ចាស់ឲ្យជួយព្រះនាងម្ដងនេះទៀត ៗ រួចស្រាប់តែមានភ្លៀងធ្លាក់មកយ៉ាងច្រើនទាល់តែលិចជើងសេះត្រឹមជង្គង់, ទឹកភ្លៀងនេះក្លាយជាទឹកកករឹងដូចថ្ម សេះរកកំរើកជើងមិនបាន ៗ ព្រះនាងឃើញហេតុអស្ចារ្យដូច្នោះ មុនដំបូងសូមអរព្រះគុណទឹងជំនួយនៃព្រះជាម្ចាស់ រួចក៏តាំងចាប់រែកទឹកដោះសេះជាខាងក្រោយ ៗ

ព្រះចៅរាជាធិរាជមានព្រះហឫទ័យកេលកលដោយកតគ្គិ ចំពោះនាងអ៊ីឡ្យេណា - សិម្ប៉ាណាជាក្រៃពេក ព្រះចៅស្ដេចទ្រង់ក្រឡេកមើលនាងដូចជាគេក្រឡេកឃើញផ្លែទម៉ាប់ទុំ ៗ ប៉ុន្តែនាងអ៊ីឡ្យេណា-សិម្ប៉ាណាគ្មានអាណិតដល់ព្រះហឫទ័យនៃព្រះអង្គបន្តិចសោះ ហើយចេះតែអាងលេសអ៊ូបន្តិចបន្តួច រួចកៀងពន្យារអាពាហ៍ពិពាហ៍ ពីថ្ងៃមួយទៅថ្ងៃមួយ ៗ លុះទីបំផុត នាងក្រាបបង្គំទូលថា: "បពិត្រព្រះមហាក្សត្រិយ៍ដ៏ថ្កុំថ្កើង! ទូលព្រះបង្គំដឹងថា ពររបស់ទូលព្រះបង្គំគឺព្រះចៅបានបំពេញសព្វគ្រប់ហើយ ៗ ទូលព្រះបង្គំនៅសល់ពរមួយទៀត ហៅថាបច្ឆិមពរ កាលណាពរនេះសម្រេចហើយ ទូលព្រះបង្គំនឹងទទួលរៀបមង្គលការជាមួយនឹងព្រះអង្គជាទៀងប្រាកដ ទូលព្រះបង្គំសូមសន្យាថ្វាយ គឺសេចក្ដីសន្យាខានចុងក្រោយបង្អស់" ៗ

ព្រះចៅមានព្រះតម្រាស់សួរថា: "ម្នាលនារីមាសបង! ព្រះរាជរដ្ឋទាំងខ្លួនបង សូមតាំងនៅក្រោមបទបញ្ជានៃអូនទាំងអស់ ៗ ចូរនាងកុំបង្អង់ឲ្យយូរដល់មួយម៉ោងក្នុងការបញ្ចេញសេចក្ដីបំណង ដ្បិតអីដូចនាងឃើញស្រាប់ បងមានចិត្តប្រតិព័ទ្ធលើរូបនាងស្ទើរដាច់ជីវិតក្នុងកាលឥឡូវនេះ គ្រាន់តែឃើញភ្នែករបស់នាងថែបព្រាយ ខ្លួនបងកើតទុក្ខស្ទើរបាត់ស្មារតីមិនដឹងគិតទៅផ្លូវណា ខ្លួនបងទៅជាមនុស្សល្ងីល្ងើ ដោយសារតែអូនឯង" ៗ

នាងអ៊ីឡេណា - សិម្យាណា ក្រាបបង្គំទូលស្នងថា: "បើដូច្នេះ, សូមព្រះអង្គយកផ្តិលពរជ័យមួយ ដែលនៅឯព្រះវិហារតូចជាខាងនាយប្រទេស (ផ្លូវដែន) មក រួចទូលព្រះបង្គំនឹងព្រមធ្វើជាអគ្គមហេសីនៃព្រះអង្គជាពិតប្រាកដ" ។

ព្រះចៅកាផាធិកដ ស្ដេចទ្រង់ត្រាស់បង្គាប់ឲ្យហៅព្រះអង្គម្ចាស់ហារហានមកទៀត ហើយទ្រង់បង្គាប់ឲ្យធ្វើដូចម្ដេច បំពេញបំណងនៃនាងអ៊ីឡេណា - សិម្យ៉ាណា ឲ្យបានរហ័សរួសរាន់ទាន់ចិត្ត ។ ព្រះនាងទៅរកសេះមួយរំពេច ។ សុរៀបកាក្រាបបង្គំទូលថា: "បពិត្រព្រះនាងជាម្ចាស់! នេះហើយជាបច្ឆិមកិច្ច ហើយជាកិច្ចយ៉ាងក្របំផុត ប៉ុន្តែសូមព្រះនាងមានសេចក្ដីទុកចិត្តលើព្រះជាម្ចាស់. យើងជិតផុតទុក្ខហើយៗ ព្រះចៅក៏ស្ដេចចង់អស់បុណ្យដែរ" ។ ជនទាំងពីររៀបប្រដាប់សត្វគ្រប់ រួចនាំគ្នាចេញទៅ ។

សេះដែលជិះអស់អាចិសត្វគ្រប់ និយាយប្រាប់ព្រះនាងទៅថា: "ផ្តិលពរជ័យនោះស្ថិតនៅលើគ្រែក្នុងកូនព្រះវិហារមួយ នៅក្រោមការព្យាបាលនៃលោកសង្ឃជាច្រើនអង្គដែលមិនសឹងទាំងយប់ទាំងថ្ងៃ ។ ប៉ុន្តែយូរៗ សម្ដេចសង្ឃរាជមកទេសនាឲ្យឆ្ងាចដល់លោកទាំងនេះម្ដង ហើយនៅមានតែភិក្ខុមួយអង្គជាអ្នកនៅចាំរក្សាផ្តិល ។ បើប្រសិនយើងទៅដល់ត្រូវចំលើពេលនោះ គឺជាវាសនាល្អរបស់យើង បើមិនដូច្នោះទេ

យើងគោងនៅទ្រាំចាំមើល ហើយមិនដឹងជាពេលណាផង ព្រោះមានមធ្យោបាយតែមួយហ្នឹង" ។

អ្នកដំណើរទាំងពីរបានដល់ប្រទេសជួរដែន ធ្ងន់ផុតទីនេះទៅ រួចទើបបានដល់កូនព្រះវិហារនោះ ។ ព្រេងវាសនារបស់ព្រះរាជធីតាធ្វើឲ្យសម្តេចសង្ឃមកដល់មុនព្រះនាងបន្តិច ហើយហៅពួកអ្នកបួសទាំងប៉ុន្មានឲ្យទៅស្តាប់ធម៌ ។ ភិក្ខុជាអ្នកចាំផ្តិល អស់កម្លាំងដោយសារចាំយាមយូរពេក ក៏ងងុយសឹង ។ ប៉ុន្តែដោយសេចក្តីប្រយ័ត្ន លោកសឹងទទឹងមាត់ទ្វារ ព្រោះគិតថាគ្មាននរណាអាចលួចបាន ។

សុរ្យាបភាប្រាប់ឧបាយដល់ព្រះអង្គម្ចាស់ក្សត្រី តើត្រូវធ្វើបែបណាដើម្បីលួចយកផ្តិលពរជ័យឲ្យបាន ។ ព្រះនាងពៅទ្រង់យាងសន្សឹមៗរហូតដល់ជញ្ជាំង ហើយដើរចំអើតព្រះបាទ សៀរៗជញ្ជាំងបានដល់ទ្វារ ។ ខណៈនោះ ព្រះនាងទ្រង់លោតកន្លងមាត់ទ្វាររហ័សដូចឆ្មាគ្មានទាំងប្រផិតលោកភិក្ខុដែលកំពុងសឹងស្រមុក កាន់យកផ្តិលត្រឡប់មកវិញ ធ្វើដូចកាលដែលចូលទៅ, ផែលឡើងលើខ្នងសេះ រួចទាញបង្ហៀរបំបែរក្បាលព្រះរាជអស្សពាហណ៍បត់រត់ទៅវិញ ។

ភិក្ខុភ្ញាក់ឡើងដោយសារស្នូរសន្ធឹក ស្ទុះតើនឡើងដឹងថាចោរភ្លាមក៏ស្រែកឆោឡោឡើង ។ សំរែកនោះសឹងធ្វើឲ្យរញ្ជួយប្រមាត់ ។ ពួកលោកសង្ឃឯទៀតរត់មកឈ្លូចរជុំគ្នាស្រែកទ្រហោយំ ដោយសេចក្តីទុក្ខ

ដែលមកពាល់ត្រូវ ។ ចំណែកសម្តេចសង្ឃរាជត្រាបថា សេចក្តីអន្តរាយមានដល់ផ្តិលពរជ័យហើយ បែរព្រះភក្ត្របំពោះទៅទិសដែលព្រះរាជធីតានឹងសុរ្យាបតាហោះទៅ, លុតជង្គង់លើកព្រះហស្តទាំងពីរឡើង រួចដាក់បណ្តាសាថា: "បពិត្រព្រះជាម្ចាស់ដ៏ចំរើន! សូមព្រះអង្គធ្វើមនុស្សទុច្ចរិតក្រៅសាសនា ដែលមានចិត្តឃោរឃៅហ៊ានលើកដៃចាប់កាន់យកផ្តិលរបស់ព្រះអង្គនេះ ឲ្យក្លាយភេទជាស្រី បើប្រុស, ហើយឲ្យក្លាយជាប្រុស បើស្រី" ។ ការបន់ស្រន់របស់សម្តេចសង្ឃ ក៏បានសម្រេចស្រេចទាន់ចិត្ត, ព្រះរាជធីតាក្លាយភេទជាមាណពមួយ មានរូបយ៉ាងឆើតគួរជាទីត្រេកត្រអាលមើល ។

កាលណាព្រះរាជបុត្រឡើងទៅគាល់ព្រះចៅរាជាធិរាជ ព្រះអង្គទ្រង់ឆ្ងល់ពេកអំពីការផ្លាស់ប្តូរភេទដូច្នេះ ។ ព្រះចៅបែបទ្រង់ជាមិនទាន់ជឿនៅឡើយ ព្រោះអ្នកបំរើព្រះអង្គហាក់ដូចជាប្លែក ព្រមទាំងឫកពានឹងអាការគ្មាហាន មិនដូចពីកាលធ្វើដំណើរចេញទៅ ។

យកផ្តិលពរជ័យហើយ ព្រះអង្គម្ចាស់ហាវហានក្រាបទូលថា: "បពិត្រព្រះចៅដ៏ទ្រង់នូវមហិទ្ធិរិទ្ធិ! ទូលព្រះបង្គំបានបំពេញការៈសព្វគ្រប់ថ្វាយព្រះអង្គហើយ ។ ឥឡូវនេះ ទូលព្រះបង្គំគិតឃើញថា កិច្ចបំរើរបស់ទូលព្រះបង្គំចំពោះព្រះចៅក៏ផុតត្រឹមហ្នឹងហើយ ។ សូមព្រះអង្គប្រកបដោយសេចក្តីសុខ ប្រកបដោយសេចក្តីសប្បាយ ហើយសូមព្រះ

អគ្គទ្រង់សោយរាជសម្បត្តិជាសន្តិសុខ ឲ្យបានអង្វែងតទៅមុខតាមបំណង នៃសេចក្ដីមេត្តានៃព្រះជាម្ចាស់" ។

ព្រះចៅរាជាធិរាជមានព្រះបន្ទូលស្ងួរសីហនាទតបថា: "យើងត្រេកអរចំពោះកិច្ចបំរើរបស់ចៅជាក្រៃលែង ។ ចូរចៅចាំចុះថាខាងក្រោយការទិវង្គតរបស់យើង គឺចៅឯងហើយដែលនឹងត្រូវសោយរាជ្យជំនួស ព្រោះយើងទាំងពីរនេះ គ្មានព្រះរាជបុត្រជាទាយាទ ។ បើព្រះជាម្ចាស់ប្រទានឲ្យមួយ ក៏ចៅឯងត្រូវនៅជាដៃស្ដាំរបស់យើងដែរ" ។

ព្រះរាជឱង្ការនេះស្ដេចទ្រង់ផ្ញើនៅកណ្ដាលពួកសេនាបតី និងព្រះរាជបុត្រទាំងប៉ុន្មាននៃស្ដេចប្រទេសរាជ ។

នាងអីឡេណា-សិម្ប៉ាណា លុះបានឃើញបដិមពររបស់នាងសម្រេចហើយ ទើបសម្រេចក្នុងចិត្តថា "ត្រូវតែបំផ្លាញព្រះចៅចោលចេញព្រោះព្រះអង្គគិតតែពីប្រើព្រះអង្គម្ចាស់ហាវហាន ជាសំឡាញ់របស់នាងឲ្យទៅបំពេញកិច្ចយ៉ាងក្រ ប្រកបដោយគ្រោះថ្នាក់ដែលអាចស្លាប់ខ្លួនក៏មាន" ។ នាងគិតតែក្នុងចិត្តថា ចុះហេតុអ្វីក៏ព្រះចៅមិនស្ដេចទៅស្វែងរកផ្តិលពារជ័យ ដោយព្រះអង្គឯង? កិច្ចនេះគឺងាយដល់ព្រះអង្គលោកពន់ពេកណាស់ ដ្បិតលោកទាំងមូលស្ដាប់បង្គាប់ព្រះអង្គទាំងអស់ ។

នាងអីឡេណា-សិម្ប៉ាណា បង្គាប់ឲ្យមនុស្សយកទឹកដោះសេះទៅកំដៅ ដើម្បីព្រះចៅរាជាធិរាជនឹងព្រះនាងស្រង់ជាមួយគ្នា ។ វេលាដែល

ជនទាំងពីរកំពុងងូត នាងអ៊ីឡេណា សិម្យ៉ាណាហៅសេះឈ្មោលឲ្យផ្លុំទឹកដោះឲ្យត្រជាក់ ។ ប៉ុន្តែសេះនោះផ្លុំខ្យល់ត្រជាក់ត្រង់កន្លែងរបស់នាងដោយរន្ធច្រមុះម្ខាង, ផ្លុំនូវខ្យល់យ៉ាងក្ដៅ ត្រង់កន្លែងរបស់ព្រះចៅដោយរន្ធច្រមុះម្ខាងទៀត ។ ព្រះរាជាក្ដៅពេកទាល់តែព្រះអង្គនៃព្រះមហាក្សត្រិយ៍រលួយ ហើយព្រះអង្គក៏ទ្រង់ព្រះសុវណ្ណគតក្នុងខណៈនោះមួយរំពេច ។

ព្រះរាជទិវង្គតនៃព្រះមហាក្សត្រាធិរាជ ព្រួរខ្ចារមួយរំពេចពេញរដ្ឋទាំងមូល ហើយមហាជនមកជាអ៊ឹកអធឹកពីទិសផ្សេងៗ ដើម្បីធ្វើបុណ្យបូជាព្រះសពនៃព្រះចៅ ។ រួចនាងអ៊ីឡេណា សិម្យ៉ាណា មានវាចាទៅកាន់ព្រះអង្គម្ចាស់ហាវហានថា: "គឺព្រះអង្គហើយដែលបាននាំទូលព្រះបង្គំមកក្នុងទីនេះ បាននាំមេសេះទាំងឡាយមកឲ្យទូលព្រះបង្គំ បានសម្លាប់យក្សដែលឆក់ទូលព្រះបង្គំ បានយកផ្ដិលពរជ័យមកឲ្យទូលព្រះបង្គំ, បើដូច្នេះ គឺទ្រង់ហ្នឹងហើយនឹងជាព្រះស្វាមីរបស់ទូលព្រះបង្គំ ! ត្រូវយើងចុះស្រង់ទឹកដោះជាមួយគ្នា រួចកិច្ចនេះហើយកាលណា យើងនឹងរៀបអាពាហ៍ពិពាហ៍មង្គលផ្សំផ្គុំគ្នាជាស្វាមីភរិយា" ។

ព្រះអង្គម្ចាស់ហាវហាន ទ្រង់មានព្រះរាជឧង្ការឆ្លើយតបថា: "អើ បើនាងមើលចំលើខ្លួនយើងហើយ យើងនឹងយកនាងជាមហេសី ។ ប៉ុន្តែក្នុងកន្លែងយើង សូមនាងជ្រាបថា: យើងចង់ឲ្យមាន់ឈ្មោលទេជាអ្នករងាវ" ។

ជនទាំងពីរមានសេចក្តីព្រមព្រៀងគ្នាកើតហើយ ៗ ក៏ចុះស្រង់ទឹកដោះទាំងពីរព្រះអង្គ ៗ នាងអឺឡេណា-សិម្យ៉ាណា ហៅសេះឈ្មោលរបស់នាងមកឲ្យផ្ញុំទឹកដោះឲ្យ, ព្រះចៅកជាធិកជថ៌ហៅសុវ្យាបកាមកឲ្យផ្ញុំដែរ, ម្ល៉ោះហើយសត្វទាំងពីរប្រកួតប្រណាំងវិទ្ធិគ្នា ដើម្បីធ្វើឲ្យម្ចាស់រៀងខ្លួនបានសុខស្រួល ៗ

លុះព្រឹកឡើងអាពាហ៍វិវាហមង្គលរវាងជនទាំងពីរ ក៏តាំងឡើងជាអឹកអធឹក ៗ រួចព្រះអង្គម្ចាស់ហារហាន ទ្រង់ស្តេចឡើងសោយរាជសម្បត្តិជាស្តេចចក្រពត្រាធិកជស្នងព្រះចៅកជាធិកជ ដែលទ្រង់ទិវង្គតហើយ ៗ វិធីរៀបមង្គលការតាំងនៅអស់ ៣ សប្តាហ: ហើយមនុស្សម្នាប្រជាជនបានសេចក្តីរីករាយដោយសារឥទ្ធិពល និងផលបុណ្យបារមីនៃព្រះចៅថ្មី ដែលព្រះជាម្ចាស់ប្រទានថ្វាយ ៗ

ស្តេចទាំងពីរព្រះអង្គ គឺ ស្វាមីនិងអគ្គមហេសី សោយរាជ្យជាសុខ ប្រកបដោយទសពិធរាជធម៌ ទំនុកបំរុងប្រជាជនដែលកំសត់ទុគ៌តបង្ហាញមធ្យោបាយដែលនាំឲ្យកើតទ្រព្យសម្បត្តិ ហើយមិនដែលធ្វើទុក្ខបុកម្នេញបៀតបៀនអ្នកណាឡើយ ៗ

ចប់

# រឿងសាមកុក

## កណ្ឌទី ១០

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ទៅធូដំរាបថា ខ្ញុំបាទឈ្មោះទៅធូកើតនៅស្រុកចៀវកុក, កាលគ្រាកើតពួកចោរជួតក្បាលលឿងខ្ញុំបាទនាំគ្រប់គ្រួនឹងបក្សពួកប្រហែល ៥០០ នាក់ រត់មកលាក់ខ្លួនពួននៅក្នុងរូងភ្នំនេះ ហើយឲ្យបក្សពួកជញ្ជូនយកដុំថ្មមកគរទុកនៅមាត់រូងជាច្រើន សម្រាប់តស៊ូនឹងពួកចោរ, លុះមកដល់ថ្ងៃ ១ នោះ ពួកចោរលើកគ្នាមកវាយពួកខ្ញុំបាទៗ បានយកដុំថ្មណាចោលទៅត្រូវពួកចោរស្លាប់គ្រប់ដុំថ្មនោះ, ពួកចោរស្លាប់អន្តរាយជាច្រើន ចោរដែលសល់ពីស្លាប់នោះលើកគ្នាថយទៅវិញអស់, អំណើះពីនោះមក ខ្ញុំបាទនឹងបក្សពួកដាច់ស្បៀងអាហារ, មានចោរ ១ ពួកលើកគ្នាមកឃើញគោខ្ញុំបាទ ទើបយកស្បៀងមកដូរយកគោ ១ នឹមទៅ ខ្ញុំបាទក៏ព្រមដូរឲ្យ,

លុះចោរនាំយកគោទៅចម្ងាយផ្លូវ ៤១ សិន (២ គី.ម.) គោផ្អើលបោលចូលទៅក្នុងព្រៃ, ខ្ញុំបាទក៏តាមទៅ ហើយចាប់កន្ទុយគោម្ខាង ១ អូសមកដល់មាត់រូងភ្នំ ពួកចោរឃើញខ្ញុំបាទមានកម្លាំងក៏មិនអាចតាមមក ។

ចូធូតបថា យើងបានឮល្បីឈ្មោះអ្នកយូរមកហើយ, ការជួបឃើញមុខគ្នាថ្ងៃនេះ ជាបុណ្យភ័ព្វរបស់យើងៗ នឹងចិញ្ចឹមរក្សាអ្នកទុកជាទាហាន, អ្នកក៏ត្រូវមានចិត្តគិតស្រឡាញ់យើងហើយព្រមធ្វើរាជការជាមួយចុះ ។ ខៅធូឆ្លើយថា "ដែលលោកមានប្រសាសន៍មកដូច្នេះ ព្រះគុណធ្ងន់មិនមានទីបំផុត ខ្ញុំបាទសុខចិត្តព្រមចូលនៅធ្វើការជាមួយនឹងលោកតទៅ" ដូច្នេះហើយ ក៏ប្រើពួករបស់ខ្លួនម្នាក់ឲ្យវិលទៅនាំយកត្រីបត្រនឹងស្លាក្របក្សពួកនឹងហោងីនឹងបក្សពួកចោរ ២០០ ប្រាយ ចេញមកចូលនៅនឹងចូធូៗ ឃើញដូច្នោះ ក៏មានសេចក្ដីត្រេកអរពន់ប្រមាណ ទើបតាំងខៅធូជាមេទាហានឯក (ពាក្យចិនហៅថា តោអ៊ុយ) ហើយឲ្យមាសប្រាក់គ្រឿងសម្លៀកបំពាក់ដល់បក្សពួកខៅធូថែមទៀត ។ ឯខ្លួនហោងីនឹងអ៊ុយសៀវនោះ ចូធូឲ្យនាំយកទៅសម្លាប់ចេញ ហើយឲ្យកាត់ក្បាលយកមកដោតទុកនៅមុខបន្ទាយ មិនឲ្យអ្នកឯទៀតយកជាបែបយ៉ាង ៗ រួចហើយចូធូក៏លើកទាហានទៅស្រុកអៀនសៀ ។

ហៃហ្វូទនឹងចោយ៉ិនបានឮដំណឹង ក៏នាំគ្នាចេញមកទទួលចូធូចូលទៅក្នុងស្រុក ហើយជំរាបចូធូថា ខ្ញុំបាទបានឮកិត្តិស័ព្ទថា លីហងនឹង

ស៊ីឡាន់ ដែលលីប៉ោឲ្យទៅនៅរក្សាស្រុកគុនជីវនោះ ឥឡូវនេះពួកទាហាន អត់ស្បៀងអាហារណាស់ តែងលើកគ្នាចេញទៅភតត្បាតវាយដណ្ដើមយកទ្រព្យរបស់អាណាប្រជានុរាស្ត្រ, ឯពួកទាហានក្នុងស្រុកនោះក៏មានស្កួបស្ដើងទេ ដូច្នេះសុំឲ្យលោកលើកពលរេហ៍ត្រឡប់ទៅវាយយកស្រុកគុនជីវនោះក៏នឹងបានដោយងាយ ។ ប៊ួយល់ព្រមតាមក៏លើកទាហានទាំងឡាយទៅវាយយកស្រុកគុនជីវនោះ ។

ឯលីហាំងនឹងស៊ុឡាន់ បានឃើញកងទ័ពប៊ួលើកទៅព័ទ្ធស្រុកក៏លើកទាហានចេញមកតទល់នឹងទ័ពប៊ួ ខៅជូឃើញដូច្នោះសុំខ្លួនចេញទៅតទល់យកអាសា ប៊ួត្រេកអរណាស់ចាត់ខៅជូឲ្យចេញទៅ ។ ខៅជូជិះសេះកាំខ្លួនចេញទៅតយុទ្ធនឹងលីហាំងបាន ៣ ក្បួន, យកខ្លួនចាក់លីហាំងធ្លាក់ពីលើសេះស្លាប់ ។ ស៊ុឡាន់ឃើញដូច្នោះមានសេចក្ដីភ័យណាស់ ប្រាសគេចខ្លួននាំពួកទាហានវិលចូលទៅក្នុងកំពែងស្រុកវិញ, ទទួលជួបប្រទះនឹងលីតៀន លើកទាហានស្កាត់ជាប់ពីមុខត្រង់គូកំពែងស្រុក, ស៊ុឡាន់ក៏ញាក់សេះបែរមុខចូលទៅក្នុងព្រៃ ។ ទទួលលីយ៉យឃើញក៏ជិះសេះស្ទុះមកស្ទាក់ ហើយលើកធ្នូបាញ់ត្រូវស៊ីឡាន់ធ្លាក់ពីលើសេះស្លាប់ ។ កងទ័ពស៊ីឡាន់ក៏បែកបាក់ខ្ចាត់ខ្ចាយអស់ទៅ ។

ខណៈនោះ ប៊ួក៏វាយយកស្រុកគុនជីវបាន ហើយឲ្យខៅជូនឹងតៀនអ៊ុយលើកពលទាហានជាកងមុខ, ឲ្យហែហូទុននឹងហែហូអៀន

ជាកងស្តាំ, ឲ្យលីតៀនទឹងង៉ាក់ជិនជាកងឆ្វេង, ខ្ទនបូឆ្វូឯងជាកងល្វង, អ៊ុកិមទឹងលីយ៉ាយជាកងក្រោយ លើកទ័ពទៅវាយយកស្រុកប៉ាក់អៀង ៗ

ឯលីប៉ោបានដឹងដូច្នោះ ក៏លើកទាហានចេញមកទល់ទ័ពបូឆ្វូ ៗ តាន់កុងហាមលីប៉ោថា ដែលលោកទឹងស្រុតលើកទ័ពចេញទៅនោះ ខ្ញុំបាទឃើញការណ៍មិនស្រួល សុំឈប់បង្អង់ចាំពួកទាហានដែលចេញទៅរកស្បៀងអាហារនោះវិលត្រឡប់មកជួបជុំគ្នាសិន សឹមលើកចេញទៅច្បាំងទឹងបូឆ្វូបុះ ៗ លីប៉ោតបថា កើតមកជាជាតិទាហានហើយ ទឹងត្រូវកោតខ្លាចសឹកសង្គ្រាមធ្វើអ្វី ៗ លីប៉ោមិនព្រមស្ដាប់ពាក្យតាន់កុងរំលឹក ក៏លើកទាហានចេញពីស្រុកទៅ ៗ លីប៉ោជិះសេះកាំទ្វូនទៅដល់មុខកងទ័ពបូឆ្វូហើយស្រែកប្រកាសថា នរណាមានថ្វីដៃខ្លាំងពូកែតស៊ូទឹងយើងបាន ក៏ឲ្យរៀបខ្លួនចេញមកចុះ ៗ ខៅធូបានឮដូច្នោះខឹងណាស់ បរសេះកាំទ្វូនចេញមកប្រយុទ្ធគ្នាទឹងលីប៉ោបាន ២០ ក្ទង មិនបានចាញ់ឈ្នះគ្នា ៗ បូឆ្វូឃើញថាខៅធូម្នាក់ឯងយកជ័យជំនះពីលីប៉ោមិនបាន ក៏ប្រើតៀនអ៊ុយចេញទៅជួយខៅធូតទឹងលីប៉ោទៀត ៗ ឯហែហួទុន, ហែហួអៀន, ង៉ាក់ជិនទឹងលីតៀនដែលជាកងឆ្វេងស្ដាំ នាំគ្នាបរសេះចេញទៅចោមព័ទ្ធលីប៉ោជុំវិញ ៗ លីប៉ោកាប់ការពារទំលាយក្នុងចំណោមទ័ពគ្រប់មេទាំង ៦ លុះឃើញថាកំឡាំងខ្លួនទឹងទប់ទល់ពុំឈ្នះ ក៏ពានបញ្ចុះស្លុះចេញទៅបាន ហើយវិលចូលទៅដល់កំពែង ៗ ឯតៀនសី

ដែលនៅលើសែនបន្ទាយ ឃើញលីប៉ោត់ត្រឡប់ចូលមកក៏បង្ខំឲ្យប័ក្ស ពួកចេញទៅអ្នកស្រុកនាក់ស្ពានធ្ងន់កំពែងនោះផ្ដាក់អស់ មិនឲ្យលីប៉ោស្ទុះចូលទៅបាន ៗ លីប៉ោបរសេះនាំទៅទ្វារទីងមាត់ទ្វារកំពែងស្រុកនោះឡើង ទាហានខាងក្នុងលើកស្ពានទទួល ៗ គៀនស៊ុំឆ្លើយពីក្នុងកំពែងមកវិញថា យើងចូលទៅខាងធ្ងរហើយ អ្នកកុំចូលមកស្រុកយើងមិនបានទេ ៗ លីប៉ោបានព្ទចញាស់ខឹងណាស់ ស្រែកដេរគៀនស៊ុំជាពាក្យអាស្រូវកាសផ្សេង ៗ ហើយបរសេះនាំទាហានស្ទុះកាត់ត្រឡប់ទៅស្រុកតាន់លឺ ៗ តាន់គុងឃើញដូច្នោះ ក៏នាំគ្រប់គ្រងលីប៉ោតាមទៅ ៗ

ប៊ូធូក៏លើកកងទ័ពចូលទៅក្នុងស្រុកប៉ាក់អៀងបាន ហើយឲ្យហៅខ្វនគៀនស៊ុំមកនិយាយថា ដែលគៀនស៊ុំមានសំបុត្រទៅបញ្ឆោតយើងឲ្យលើកទ័ពមកចាញ់ប្រៀបលីប៉ោពីដាន់មុន នោះមានទោសជាទំហំខ្លាំងណាស់; គ្រានេះគៀនស៊ុំបានធ្វើសេចក្ដីគាប់លុបទោសចាស់ឲ្យមនុស្សអ្នកស្រុកនាក់ស្ពានមិនឲ្យលីប៉ោធ្ងន់ទៅបាន នេះជាគុណនាំឲ្យលុបទោសអស់ហើយ ៗ

ឡៅហ៊ូនិយាយនឹងប៊ូធូថា ដែលលីប៉ោត់ទៅគ្រានេះ បើលោកនឹងឲ្យលះបោលយូរឃើញថា នឹងមានកំឡាំងគិតការឡើងវិញបាន ចបមាដូចយកខ្លាទៅលែងក្នុងព្រៃ យូរទៅនឹងចាប់យកមកវិញដោយលំបាក ៗ ប៊ូធូស្ដាប់ឃើញត្រូវ ទើបចាត់ឲ្យឡៅហ៊ូជាមេរក្សាទាហាននៅការពារ

ស្រុកប៉ាក់អៀង ៗ ខុនបូឆ្ងងប្រមូលសេនាទាហានតូចធំផ្ដុំជាកងទ័ពលើកតាមលីប៉ោទៅស្រុកតាន់លីវ ៗ

ឯតៀវលៀវ, ចុងប៉ា, ហោសេង, កោស៊ុន ដែលជាសេនាលីប៉ោផ្ដុំនាំទាហានទៅរកស្បៀងអាហារនោះមិនបានដឹងថា លីប៉ោបែកទ័ពរត់ត្រឡប់ទៅស្រុកតាន់លីវសោះ ក៏នាំគ្នាពតត្បាតវាយប្លន់ចក់ដណ្ដើមទ្រព្យរបស់អស់បណ្ដាអ្នកស្រុក ក្នុងស្រុកប៉ាក់អៀងជាចលាចល ពស្ដ្របានសេចក្ដីទុក្ខទល់ក្ដៅក្រហាយណាស់ ៗ

កាលលីប៉ោរត់ពីបូឆ្ងទៅដល់ស្រុកតាន់លីវនោះ លុះដឹងថាបូឆ្ងលើកទ័ពតាមមក ក៏មិនបានបេញតតាំង សំងំនៅក្នុងកំពែងស្រុកគាន់តែប្រឹក្សាទឹងតៀវមៅជាចៅហ្វាយស្រុក ហើយឲ្យទាហានឡើងយាមល្បាតលើសែនបន្ទាយការប្រយ័ត្នការជុំវិញ ៗ ឯបូឆ្ងនោះមិញប្រើសេនាទាហានឲ្យលើកចូលទៅបោះទ័ពទល់នឹងជើងកំពែង ចំនួន ១០ ថ្ងៃមិនឃើញលីប៉ោចេញមកតសោះ ៗ ទ័ពបូឆ្ងនោះ ក៏ដាច់ស្បៀងអាហារ, ទទួលទេសកាលស្រូវកោដន៍សាលីទៀបទឹងទុំ បូឆ្ងក៏ប្រមូលផ្ដុំកងទ័ពលើកត្រឡប់ទៅវិញនៅចម្ងាយពីស្រុកនោះប្រហែល ៤០០ ស៊ិន (១៦ គី.ម.) ឲ្យទាហានកាន់កណ្ដៀវចុះច្រូតស្រូវកោដន៍សាលីរបស់អ្នកស្រុកពេញស្រែនិមួយៗ ហើយនាំយកមកបុកដាំឲ្យទាហានបរិភោគ ៗ ខណ:នោះ មានមនុស្សទៅប្រាប់លីប៉ោថា ទាហានបូឆ្ងដាច់ស្បៀង

អាហារ ថយទ័ពត្រឡប់ទៅប្រូតស្រូវ ។ លីប៉ោក៏នាំទាហានទៅចាប់មនុស្សប្រូតស្រូវ, ទាហានចូឆូនោះ លុះឃើញលីប៉ោនាំគ្នារត់ចូលបន្ទាយ, លីប៉ោបរសេះស្ទុះដេញតាមទៅដល់ទល់នឹងបន្ទាយចូឆូ ឃើញខាងត្បូងផ្លូវមានព្រៃធំ ក៏គិតព្យាយាមក្រែងចូឆូបង្កប់ទាហាននៅទីនោះ លីប៉ោក៏ត្រឡប់សេះនាំទាហានចូលក្នុងកំពែងវិញ ។

ចូឆូដឹងដូច្នោះ ក៏ប្រឹក្សានឹងសេនាទាហានថា ដែលលីប៉ោចេញមកដេញមនុស្សប្រូតស្រូវ ហើយវិលត្រឡប់ទៅជាប្រញាប់នោះ ប្រហែលគិតក្រែងថាយើងបង្កប់ទាហានទុកក្នុងព្រៃ ឥឡូវនេះយើងឲ្យយកទង់ជ័យទៅដោតពាយក្នុងព្រៃឲ្យច្រើន ឲ្យទាហាននៅក្នុងបន្ទាយតែ ៥០ នាក់ យើងនឹងទាហានទាំងអស់នាំគ្នាទៅបង្កប់ក្នុងអូរក្រោយបន្ទាយវិញ បើលីប៉ោមកឃើញគង់នឹងយកភ្លើងអុជព្រៃឆេះអស់ ហើយចូលហួសទៅក្បែរបន្ទាយឃើញទាហានទាំងឡាយនៅស្ងៀម ក៏នឹងលើកចូលទៅវាយយកបន្ទាយនោះ យើងត្រូវឲ្យទាហានវាយគងឃោះនឹងស្គរជាសញ្ញាឲ្យព្រួទ្រខ្ទារឡើង ហើយសំរុកលើកទាហានដែលបង្កប់ពីក្រោយចេញព័ទ្ធបណ្ដោយមក ឃើញថានឹងចាប់លីប៉ោបានដោយងាយ ។ ទាហានក្នុងកងទ័ពស្ដាប់ឃើញត្រូវ; លុះពេលយប់ជ្រៅ ចូឆូក៏ប្រើឲ្យទៅធ្វើតាមដែលគិតទុកនោះគ្រប់ប្រការ ។

លុះពេលព្រឹកភ្លឺស្រាង លីប៉ោប្រឹក្សានឹងតាន់កុងថា ពីម្សិលមិញយើងបានទៅដេញចាប់ទាហានចូឆូដែលលួចប្រូតស្រូវ យើងដឹងថា

បូឆ្បបង្កប់ទាហាននៅក្នុងព្រៃជាច្រើនបានជាត្រឡប់មកវិញ ថ្ងៃនេះយើងនឹងលើកទាហានទាំងអស់ទៅដុតព្រៃ ដែលបង្កប់ទាហាននោះឲ្យឆេះអស់ ហើយសុំលើកទ័ពទៅខ្ទប់ពាយយកបន្ទាយបូឆ្បឲ្យបាន ៗ តាន់កុងឃាត់ថា បូឆ្បនោះមានគំនិតគិតក្នុងកលសង្គ្រាមជាច្រើនណាស់, ដែលលោកនឹងលើកទ័ពចេញទៅច្បាំង ត្រូវតែរាំងមើលកល់ការឲ្យស្រួលបួលសិន ៗ លីប៉ោមិនព្រមស្ដាប់ពាក្យតាន់កុង ឲ្យតាន់កុងនៅរក្សាស្រុកជាមួយនឹងតៀវមៅ ៗ ខ្លួនលីប៉ោឯងលើកទាហានចេញទៅពីស្រុកដល់ទៅព្រៃខាងឆ្វេងផ្លូវ ឃើញទង់ជ័យដោតនៅជាច្រើនក៏គិតថា "ប្រហែលបូឆ្បឲ្យទាហាននៅក្នុងព្រៃនោះ" ហើយក៏លើកទ័ពពាយខ្ទប់ជុំវិញពីក្រៅ ហើយឲ្យយកភ្លើងដុតព្រៃនោះឆេះឡើងទាំង ៤ ទិស, មិនឃើញមានមនុស្សម្នាក់សោះ ក្រឡេកមើលទៅក្នុងបន្ទាយស្ងាត់ជ្រងំ ខំលើកទាហានចូលទៅ ស្រាប់តែឮសំឡេងឃោះគងទូងគើរ, លីប៉ោតក់ស្លុតឈប់ស្ដាប់នៅទីនោះ ស្រាប់តែឮសន្ធឹកកងទ័ពស្រែកហ៊ោក្រោយបន្ទាយ ហើយពាយទាហានព័ទ្ធមក លីប៉ោគ្រវីទួនបរសេះបួលទៅតយុទ្ធ ស្រាប់តែឮផាវអុជឡើងជុំវិញខ្លួន ៗ ហែហ៊ុន ហែហ៊ូអៀន ខៅជូ តៀនអ៊ុយ លីតៀនទឹងផ៉ាក់ជិន ទាំង ៦ នាក់នេះក៏លើកទាហានឡើងពីក្នុងអូរឈូឆេរចេញមកព័ទ្ធរុំជុំវិញលីប៉ោ ៗ ក៏ប្រកាប់ជាប់ដៃទាំងសងខាង ឃើញកំឡាំងទឹងតាំងតពុំបាន ក៏បង្រួសពលទាហានរត់ចេញទៅជាមួយនឹង

សេងកៀម ៗ ង៉ាក់ជិន ឃើញដូច្នោះ ក៏បរសេះដេញតាមពីក្រោយ ហើយយិតធ្នូបាញ់ត្រូវសេងកៀម ធ្លាក់ពីលើសេះស្លាប់ ៗ ឯទាហានលីប៉ោក៏របួសពិការស្លាប់ជាច្រើន, ដែលសល់នៅប៉ុន្មាន ក៏បំពានរត់យកតែខ្លួនទៅចូលក្នុងកំពែងស្រុកវិញ ហើយយកសេចក្តីនោះប្រាប់តាន់-កុងគ្រប់ប្រការ ៗ ឯតាន់កុងក៏ស្លុតរន្ធត់ចិត្តគិតថា "ទាហានក្នុងស្រុកតាន់លីវនេះនៅតិចណាស់ ឃើញថានឹងតទល់នឹងកងទ័ពចូចូមិនបាន" ហើយក៏នាំគ្រប់គ្រួលីប៉ោរត់ដោះខ្លួនចេញពីស្រុកនោះទៅ ៗ

បំណែកចូចូ លើកកងទ័ពមកខ្ទប់វាយយកស្រុកតាន់លីវនោះបាន ហើយឲ្យទាហានយកភ្លើងដុតបំផ្លាញផ្ទះសម្បែងអ្នកស្រុកឆេះអស់ ៗ តៀវបៀវនោះស្ទុះរត់ទៅមិនទាន់ក៏ស្លាប់ក្នុងភ្លើង ៗ ឯតៀវមៅបៅហ្វាយស្រុកនោះក៏រត់ទៅនៅទឹងអ៊ូនស៊ុតបៅហ្វាយស្រុកឡាំយ៉ុង; អស់បណ្តាស្រ្តីដែលនៅក្នុងស្រុកតាន់លីវទាំងប៉ុន្មាន បាននាំគ្នាចុះចូលទៅនៅជាពួកម៉ាករបស់ចូចូទាំងអស់ ៗ ឯចូចូនោះក៏ត្រឡប់បានជាធំ ក្នុងអាណាខែត្រទិសបូព៌ាជាច្រើនតំបន់ ហើយឲ្យតែងតាំងធ្វើបន្ទាយវាយតកំពែងជីកគូអូរស្នាមភ្លោះ ទុកគ្រប់ចន្លោះខែត្រមួយៗ ហើយឲ្យហ្វឹកហាត់សេនាទាហានបានជាច្រើន ៗ

ឯលីប៉ោរត់ទៅដល់កណ្តាលផ្លូវ ទទួលជួបប្រទះនឹងតៀវលៀវ ចុង-ប៉ា ហោសេង នឹងកោស៊ុន ដែលលើកទៅរកស្បៀងអាហារ តាំងពីគ្រា

ដែលនៅក្នុងស្រុកប៉ាក់អៀងនោះ ។ លីប៉ោពណ៌នាពីរឿងប្រាប់មិនទាន់ចប់ពាក្យ ឆាកទៅឃើញតាន់កុងនាំគ្រប់គ្រងតាមទៅទាន់ លីប៉ោក៏បានអន់ស្រាកកំហឹងទុក្ខព្រួយ ហើយនាំគ្រប់គ្រងនឹងសេនាទាហានទៅតាំងបន្ទាយនៅក្បែរមាត់ទន្លេដែនស្រុកតាន់លីវ ហើយប្រឹក្សានឹងតាន់កុងនឹងសេនាទាហានទាំង ៤ នាយថា យើងបែកទ័ពនឹងចូចូតែមកគ្រានេះ មិនត្រូវគិតកោតញញើតរំពឹងទៅទៀតទេ ត្រូវគិតច្នៃរកឧបាយនឹងលើកទ័ពត្រឡប់ទៅច្បាំងនឹងចូចូ យកស្រុកយើងវិញឲ្យបាន ។

តាន់កុងឃាត់ថា ឥឡូវនេះចូចូមានទាហានរេហ៍ពលជាច្រើនណាស់, ខាងអាណាខែត្របូព៌ាទិស នៅក្នុងអំណាចត្រួតត្រាពធការរបស់ចូចូទាំងអស់; ទាហានរបស់យើងក៏មានតិចណាស់ មិនជួនការហើយកំពុងហត់ទៀយ, ដែលលោកនឹងបង្ខំលើកទៅតតាំងច្បាំងកាច់យកដោយរហ័ស មិនមែនបានដោយងាយទេ ត្រូវតែនាំគ្រប់គ្រងទៅរកទីសំណាក់អាស្រ័យឲ្យមាំមួនសិន រួចសឹមគិតការតទៅ ។ លីប៉ោស្ដាប់ឃើញត្រូវក៏សួរតាន់កុងថា បើយើងនឹងនាំគ្រប់គ្រងទៅពឹងពាក់សំណាក់នៅនឹងអួនសៀវចៅហ្វាយស្រុកគីជីវ អ្នកនឹងឃើញយ៉ាងដូចម្ដេច? ។ តាន់កុងឆ្លើយថា ដែលលោកគិតនោះគួរហើយ តែសុំឲ្យចាត់បំរើទៅស៊ើបស្ដាប់គតិស័ព្ទអ្នកស្រុកគីជីវឲ្យដឹងសិន ជាអួនសៀវនឹងព្រមឲ្យយើងនៅដែរឬទេ? ។ លីប៉ោក៏យល់ព្រម ទើបចាត់បំរើឲ្យចេញទៅស្រុកគីជីវ ។

ឯអួនសៀវចៅហ្វាយស្រុកគីដីវតាំងពីឮកិត្តិស័ព្ទថា ប្អូននឹងលីប៉ោច្បាំងគ្នានៅស្រុកប៉ាក់អៀង ទើបប្រឹក្សានឹងស៊ុមផូយថា លីប៉ោនឹងប្អូនច្បាំងគ្នាគ្រានេះ បើខាងលីប៉ោឈ្នះប្អូន តើអ្នកនឹងយល់ឃើញយ៉ាងម្តេច ? ។ ស៊ុមផូយឆ្លើយថា ឯសន្តានចិត្តលីប៉ោនោះជាមនុស្សកាចសាហាវដូចខ្លា បើបានស្រុកប៉ាក់អៀងហើយ គង់នឹងកំរើបចិត្តគិតកន្លងមករាយយកស្រុកយើងទៀតមិនខាន សូមឲ្យលោកកេណ្ឌទាហាន ៥ ម៉ឺន លើកទៅជួយប្អូនច្បាំងសម្លាប់លីប៉ោចេញឲ្យបាន ទើបស្រុកយើងនឹងបានសេចក្តីសុខ ។ អួនសៀវយល់ត្រូវ ក៏ឲ្យឆាន់លៀងលើកទាហាន ៥ ហ្មឺនទៅជួយប្អូន ។

ខណៈនោះបំរើលីប៉ោ ដែលទៅស៊ើបស័ព្ទស្តាប់ដំណឹងឯស្រុកគីដីវនោះ ទើបនឹងទៅដល់ពាក់កណ្តាលផ្លូវបានដឹងឮដូច្នោះ ក៏នាំសេចក្តីនោះវិលមកប្រាប់លីប៉ោវិញថា ឥឡូវនេះអួនសៀវឲ្យឆាន់លៀងនាំទាហានទៅជួយប្អូនច្បាំងតនឹងលោកហើយ ។ លីប៉ោឮដូច្នោះ ក៏ភ័យណាស់ សួរតាន់គុងថា បើអួនសៀវជាចិត្តមួយនឹងប្អូនហើយ តើយើងនឹងគិតយ៉ាងម្តេច ? ។ តាន់គុងថា ខ្ញុំបានឮដំណឹងច្បាស់ថា តោកៀមលើកស្រុកឈីដីវឲ្យឡេវពីធ្វើចៅហ្វាយស្រុកហើយ ឡេវពីនោះជាមនុស្សចិត្តល្អធូរទូលាយពេះពាយរាប់អានអ្នកទាំងពួងណាស់ សូមលោកនាំគ្រប់គ្រួ ទៅអាស្រ័យនៅនឹងឡេវពីក្នុងក្រុងឈីដីវចុះ មុខជា

ទៀតមិនសូវឲ្យផ្លូវមេត្រីនឹងលោកទេ ។ លីប៉ោយល់ត្រូវក៏នាំគ្រប់គ្រួ ទៅរកទៀតី លុះចូលទៅដល់ស្រុកឈីជីវហើយ ក៏ឲ្យបំរើចូលទៅជំរាបទៀតីថា លីប៉ោនឹងសូមមកសំណាក់ពឹងពាក់នៅនឹងលោកតទៅ ។

ទៀតីប្រឹក្សានឹងបីតុកថា លីប៉ោបរាជ័យនឹងដៃប៉ូប៉ូ ឥឡូវនេះរត់មកទីពឹងនៅនឹងយើង ។ ត្រូវតែចេញទៅទទួលឲ្យចូលមកក្នុងស្រុក ។ បីតុកឆ្លើយថា សន្តានចិត្តលីប៉ោនោះទុរយសកំណាចកាចសាហាវដូចខ្លា, ឥឡូវនេះខ្វះរាជូចខ្លាឆ្លាក់អណ្តូង បើលោកនឹងយោងលើកយកមកឲ្យចំណីផ្សាំង លុះរាមានកម្លាំងកាលណានឹងទំពាក្បាលយើងវិញ ។ ទៀតីតបថា ប៉ូប៉ូនោះក៏ជាមនុស្សកាចចិត្តអាក្រក់ ឥឡូវនេះបានជាធំត្រួតលើអាណាខេត្តខាងទិសបូព៌ាទាំងអស់ បើលីប៉ោរាយ័យកបានស្រុកគុនជីវិញ ស្រុកយើងក៏គង់នឹងបានសេចក្តីសុខផង ប៉ូប៉ូក៏មិនអាចរំលងមករាយស្រុកយើងទេ ឥឡូវនេះ លីប៉ោបានជាបែរមុខមករកយើងហើយ បើយើងព្រងើយកន្តើយក៏ដូចគ្មានមេត្តាសោះ ។ តៀវហ៊ុយឆ្លើយថា ចិត្តរបស់លោករមែងជូរទូលាយពេះពាយព្រប់អានមនុស្សទាំងវៀចទាំងត្រង់ បើលោកនឹងចង់ទទួលយកលីប៉ោមកទុកក៏តាមអធ្យាស្រ័យលោកចុះ តែឲ្យគិតរាំងហេតុផលឲ្យល្អ ។

ទៀតីក៏នាំក្អូនអ្វូ តៀវហ៊ុយ និងទាហានទាំងពួង ចេញមកទទួលលីប៉ោ ចម្ងាយផ្លូវប្រហែល ៣០០ សិន (១២ គី.ម.) ហើយនាំត្រឡប់

ចូលមកក្នុងស្រុក រួចអញ្ជើញលីចៅឲ្យអង្គុយក្នុងទីសមគួរ ។ លីចៅ ក៏ពណ៌នាប្រាប់ព្រឿងឲ្យឡោតពីស្តាប់គ្រប់ប្រការថា ពីដើមអងអ៊ុននឹងខ្លួនខ្ញុំគិតគ្នាប្រាថ្នាសម្លាប់តាំងតុៈដែលជាសត្រូវរាជសម្បត្តិ ក៏បានដូចចិត្ត, លុះលីឈុយគុយគីបានជាធំឡើង ក៏ឲ្យរកឧបាយនឹងសម្លាប់ខ្ញុំវិញ ខ្ញុំបានដឹងការណ៍ទាន់ក៏រត់ចេញពីទីក្រុងមក បានទៅរកទីពឹងនៅជាច្រើនតំបន់ ក៏មិនសម្រេចតាមប្រាថ្នា លុះខ្ញុំបានទៅនៅនឹងគៀវម៉ៅចៅហ្វាយស្រុកគាន់លីវ វេលាណា ចូឆ្វូក៏លើកទ័ពតាមព្យាបាទទៅវាយយកស្រុកនោះបាន ខ្ញុំបានស៊ើបដឹងថា លោកលើកទ័ពមកជួយគោកៀម ខ្ញុំក៏មានសេចក្ដីត្រេកអរ បានជាលើកទ័ពទៅវាយយកស្រុកគុនជីវឲ្យជាកង្វល់ ដើម្បីនឹងជួយផ្ដល់កុំឲ្យមានរវល់ដល់ស្រុកបានឡើយ គ្រានេះខ្ញុំក៏បានបែកទ័ពបរាជ័យនឹងចូឆ្វូងទៀត ខូចខាតទាហានក៏ច្រើន បានជាចូលមកទីពឹងអាស្រ័យនឹងលោក ដើម្បីនឹងឈប់សំណាក់ កាលណាស្បើយធូរ.ក៏នឹងគិតការធំតទៅទៀត តែថាឥឡូវនេះខ្ញុំមិនទាន់បានដឹងច្បាស់ជាចិត្តលោកព្រមរួមគិតគំនិតមួយនឹងខ្ញុំដែរឬទេ? ។

ឡោតពីតបថា "គោកៀមអនិច្ចកម្មទៅ ស្រុកឈីជីវក៏នៅលើដៃខ្ញុំកាន់កាប់រក្សាបណ្ដោះអាសន្ន ព្រោះនឹងរកអ្នកឯណាចេះដឹងគ្រាន់ឲ្យធ្វើធំមិនបាន, ឥឡូវនេះ អ្នកមកដល់ទីឋាននេះក៏សមគួរនឹងធ្វើការរាជការបាន ខ្ញុំក៏មានសេចក្ដីត្រេកអរនឹងលើកស្រុកឈីជីវនេះ ឲ្យអ្នកធ្វើជាចៅហ្វាយ

ស្រុកចុះ ថាហើយក៏លើកត្រាស ម្រាប់ផាររនោះឲ្យលីប៉ោៗ ក៏រើកដៃនឹង ទទួលយកត្រា តែពោលក្អែកទៅឃើញក្អួនអ៊ូ តៀវហ៊ុយ ដែលឈរ ក្រោយទៀតពីបែបចំងសំបា លីប៉ោ ធ្វើជាសើចហើយឆ្លើយថា ខ្ញុំ ត្រឹមតែទីទាហានទឹងទទួលនិយាយការទៃត្រីណ្ណតែម្តង ឃើញលើស សតិបញ្ញាណាស់ ។

គាត់កុងបានឮដូច្នោះក៏និយាយថា ធម្មតាជាភ្ញៀវមករកលោកជា ម្ចាស់ផ្ទះ ណាឡើយទឹងបានរូតរះរើសយករបស់ទ្រព្យទៅជាមួយផងនោះ ក៏ជាសេចក្តីមិនគួរទេ, ឯខ្លួនលីប៉ោដែលមកសុំសំណាក់នៅទីងលោកនេះ ទឹងបានតាំងចិត្តគិតដណ្តើមយកស្រុកក៏ទេ លោកមិនត្រូវសង្ស័យអ្វី ឡើយ ។ ទៀតពីស្តាប់ហើយក៏រៀបលៀងអាហារ អញ្ជើញលីប៉ោទឹង សេនាបរិភោគ ហើយចាត់ចែងទីលំនៅឲ្យលីប៉ោសំណាក់ ។ លុះព្រឹក ឡើងលីប៉ោរៀបលៀងអាហារ អញ្ជើញទៀតពី ក្អួនអ៊ូ តៀវហ៊ុយ ទៅបរិភោគវិញ លុះបរិភោគរួចក៏អញ្ជើញទៀតពីទៅខាងក្នុង ។ ក្អួនអ៊ូ តៀវហ៊ុយតាមទៅជាមួយ ។ ពេលនោះលីប៉ោឲ្យបុត្រករិយាចេញមក គំនាប់ទៀតពីៗ រីងខ្លួនក៏ហាមឃាត់ថា កុំឲ្យគំនាប់ឡើយ ។ លីប៉ោ និយាយថា លោកប្អូនកុំព្រួយទឹងយើងដែលឲ្យករិយាបុត្រគំនាប់នេះ ។

តៀវហ៊ុយបានឮដូច្នោះក៏ខឹងញ័រ ស្រែកកំទរថាខ្លួនឯងហេតុម្តេច បានជាហ៊ានហៅបងអញថាប្អូន បងអញពេញជាពូជព្រះរាជវង្ស ឧបមា

ដូចដើមឈើស្ងួតមាស, ដែលខ្លួនអ្នកអាងថាខ្លាំងពូកែនោះ ចូររៀបខ្លួនចេញទៅល្បងថ្លៃដៃមើលបាន ២-៣ រយក្លេងចុះ ។

ទេវ្ទាពីបែរទៅនិយាយឃាត់គៀវហ៊ុយជាប្រញាប់. ក្អួនអ៊ូក៏ចាប់ដឹកដៃគៀវហ៊ុយចេញមកក្រៅ ។ ទេវ្ទាពីនិយាយនឹងលីប៉ូថា ដែលគៀវហ៊ុយនិយាយទ្រគោះឲ្យអ្នកអម្បាញ់មិញនេះ ព្រោះសេពសុរាស្រវឹងខ្លាំងណាស់ យើងសុំសំពះកុំឲ្យយកទោសឡើយ ។ លីប៉ូគ្រវីក្បាលហើយមិនឆ្លើយសោះ ។ ទេវ្ទាពីក៏លាលីប៉ូទៅវិញ លុះទៅដល់កណ្ដាលផ្លូវគៀវហ៊ុយ . ក៏បរសេះវេះត្រឡប់ទៅដល់មុខផ្ទះលីប៉ូហើយស្រែកថា អម្បាញ់មិញអញខ្លាចបងអញទេ ឥឡូវនេះបងអញទៅហើយ ឲ្យលីប៉ូចេញមកចាប់នឹងល្បងថ្លៃដៃគ្នាមើលបាន ២-៣ ក្លេង ។ ទេវ្ទាពីត្រឡេកមកក្រោយមិនឃើញគៀវហ៊ុយ ក៏ឲ្យក្អួនអ៊ូតាមទៅហៅយកខ្លួនគៀវហ៊ុយមកវិញ ។

លុះវេលាព្រឹកឡើង លីប៉ូទៅនិយាយនឹងទេវ្ទាពីថា ពីដើមខ្ញុំមកសុំអាស្រ័យនៅនឹងលោកៗក៏ព្រមឲ្យនៅហើយ តែឥឡូវនេះគៀវហ៊ុយប្អូនលោកនោះទៅនិយាយពាក្យអាក្រក់មើលងាយខ្ញុំខ្លាំងណាស់ ខ្ញុំនឹងនៅតទៅក៏គង់នឹងមានទាស់ចិត្តលោក បើដូច្នេះខ្ញុំនឹងលាលោកទៅរកទីដទៃនៅវិញចុះ ។

(មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

## ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តទៅ)

## ប្រវត្តិជាតិថៃ (សៀម)

ប្រវត្តិជាតិថៃនោះ មានអ្នកប្រាជ្ញជាតិថៃក្នុងបច្ចុប្បន្ន បានស្រាវជ្រាវ និង រៀបរៀងទុកជាច្រើនបែប-ច្រើនច្បាប់ ដូចយ៉ាង:

១- រឿងប្រវត្តិថៃ ដែលសម្តេចក្រុមព្រះយ៉ាដំរង់រាជានុភាព ទ្រង់និពន្ធរួមនៅក្នុងព្រះរាជពង្សាវតារ ច្បាប់ព្រះរាជហត្ថលេខា ទំព័រ ៥៧ ។

២- រឿងប្រវត្តិសាស្ត្រសាកល ភាគទី ១ របស់ហ្លួងវិចិត្រវាទការ ។

៣- ប្រជុំសិលាចារឹកស្យាម សម័យក្រុងសុខោទ័យ ភាគ ១ ដែលលោកសាស្ត្រាចារ្យ ហ្សកសឺដេសរួម និង រៀបរៀង បោះពុម្ពជាភាសាថៃក្នុងឆ្នាំជូត ព. ស. ២៤៦៧ ។ល។

លំដាប់នេះ ទឹងពណ៌នាប្រវត្តិជាតិថៃ ឬហៅថា សៀម ដោយសង្ខេប ។ តាមប្រាកដនៅក្នុងរឿងរ៉ាវដែលចេញឈ្មោះមកខាងលើនេះថា ជាតិថៃដើមឡើយបានតាំងតស្សរការនៅក្នុងប្រទេសចិនណាំ

ឬយុណាន នៅក្នុងដែនចិនភាគខាងត្បូង ដែលឥឡូវនេះធ្លាក់ទៅជារបស់ចិនអស់ហើយ ។

ប្រមាណតាំងពី ព. ស. ១៥០០ មក ជាតិថៃបានត្រូវជាតិចិនរុករានជាយ៉ាងខ្លាំង ហើយញឹកៗណាស់ផង ក្នុងទីបំផុតប្រទេសថៃក៏ធ្លាក់ទៅជាសម្បត្តិរបស់ចិនដរាបដល់សព្វថ្ងៃនេះ ។ ដោយហេតុត្រូវគេរុករានយ៉ាងនេះ ក្នុងពេលនោះៗ មានជនជាតិថៃភាគខ្លះ ទ្រាំនៅក្នុងប្រទេសរបស់ខ្លួនពុំបាន ក៏នាំគ្នាចុះមកអាស្រ័យនៅក្នុងប្រទេសប៉ែកខាងត្បូងជាច្រើនលើក ច្រើនដង ដរាបដល់ ព. ស. ១៧០០, ពោលដោយចំពោះគឺចុះមកអាស្រ័យនៅ តាមដាយព្រះរាជអាណាចក្រកម្ពុជាភាគខាងលើ រៀងទៅដល់ក្នុងដែនមន ។ គ្រាដែលពួកថៃមកអាស្រ័យក្នុងប្រទេសកម្ពុជានេះ ព្រះមហាក្សត្រិយ៍ខ្មែរទ្រង់ព្រះមេត្តាប្រោសឲ្យនៅដោយស្រួល តែនៅក្នុងឋានៈជាចំណុះខ្មែរ គ្មានអំណាចអ្វីក្នុងផែកគ្រប់គ្រងទេ គ្រាន់តែក្នុងតំបន់ណាមានជនជាតិថៃច្រើន រាជាភិបាលក៏តាំងថៃ ១ នាក់ជាមេឲ្យត្រួតត្រាគ្នាឯងក្នុងតំបន់នោះ ទំនងដូចដែលរាជការតាំងមេចិនក្នុងបច្ចុប្បន្ន ។ ការគ្រប់គ្រងរបស់ខ្មែរក្នុងសម័យនោះ ប្រព្រឹត្តទៅយ៉ាងធូរៗ គ្មានការបៀតបៀនឬរំលោភអ្វីឡើយ ។ ពួកថៃដែលមកនៅក្នុងប្រទេសខ្មែរ បានទទួលយកនូវអារ្យធម៌និងវប្បធម៌ភាពអំពីខ្មែរ គ្រប់មុខគ្រប់យ៉ាង មានអក្សរសាស្ត្រ លទ្ធិទំនៀម និងសាសនាជាដើម ។

លុះមកដល់ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៦ នៃប្រទេសកម្ពុជា ដែលសោយរាជ្យក្នុងរវាង ព.ស. ១៦៣២ ដល់ ១៦៥០ មានជាតិថៃ ១ នាក់ឈ្មោះ ពង្គកជ ដែលក្នុងប្រវត្តិថៃថាជាតិជាក្សត្រិយ៍ បានផ្តើមតាំងឥស្សរភាពឡើងនៅស្រុកលានណា សឹងនៅក្នុងសង្កាត់អាណានិគមរបស់ខ្មែរ ។ កាលព្រះបាទជយវរ្ម័នទី ៦ ទ្រង់ជ្រាបរឿងនោះ ក៏ត្រាស់ឲ្យលើកកងទ័ពតូចទៅកំចាយចេញ ក្នុងឆ្នាំ ព.ស. ១៦៤០, ព្រះពង្គកជមិនហានតស៊ូក៏រត់ចូលព្រៃបាត់ទៅ ស្រុកនោះក៏ត្រឡប់មកជាអាណានិគមខ្មែរដូចដើមវិញ ។

រយៈវេលាតមក ក្នុងរជ្ជកាលព្រះបាទធរណីន្ទ្រវរ្ម័ន ទី ២ ប្រទេសកម្ពុជា មានសង្គ្រាមកើតឡើងក្នុងខាងក្នុងព្រះនគរ ដោយមានក្សត្រិយ៍នឹងក្សត្រិយ៍ដណ្តើមរាជបល្ល័ង្គគ្នា ។ ក្នុងពេលនោះព្រះសូរ្យវរ្ម័នសិងជាព្រះរាជវង្ស ១ អង្គ ឃើញក្សត្រិយ៍នឹងក្សត្រិយ៍ដណ្តើមរាជបល្ល័ង្គគ្នាដូច្នោះ ទ្រង់ព្រះចិន្តាថា តែកាលណាមានសង្គ្រាមក្នុងប្រទេស តែងតែមានសឹកពីប្រទេសក្រៅលើកមកវាយផ្ទួនថែមទៀត យ៉ាងហោចណាស់ក៏គង់មានស្រុកអាណានិគមបណ្តាលបះបោរឡើង ព្រោះដូច្នោះ ទើបទ្រង់រួបរួមកងទ័ពលើកទៅកម្ចាត់ក្សត្រិយ៍អ្នកវិវាទគ្នាឲ្យរាបទាបទៅ ហើយទ្រង់ឡើងគ្រងរាជបល្ល័ង្គមានព្រះបរមនាមថា ព្រះបាទសូរ្យវរ្ម័នទី ២(១) ក្នុង ព.ស. ១៦៥៦-១៦៨៨ ។

---

១ ជាក្សត្រិយ៍រាជាធិរាជ ដែលសាងប្រាសាទនគរវត្ត គឺក្សត្រិយ៍ដែលពាក្យសាម័ញ្ញហៅថា ព្រះបទុមសុរិយវង្ស ។

ក្នុងពេលដែលមានការណ៍បះបោរក្នុងព្រះនគរនោះ ព្រះព្រហ្មរាជ ជាឱរសរបស់ព្រះពញាព្រះរាជ ឃើញបានឱកាស ក៏រួបរួមរេហ៍ពលលើក មកវាយដណ្តើមយកស្រុកលានណាអំពីខ្មែរ ជំនួសព្រះបិតាដែលរត់ចូល ព្រៃទៅនោះ វាយបានស្រុកហ្លួង-ដៀងរ៉ាយ ស្រុកពានប្អាន ស្រុកពាយៅ ស្រុកង៉ាវ លំបាង និងស្រែចើន (សឹងនៅក្នុងមណ្ឌលពាយ័ព្យ របស់ថៃសព្វថ្ងៃនេះ) មកនៅក្នុងកណ្តាប់ដៃរបស់ខ្លួន មិនត្រឹមតែ ប៉ុណ្ណោះ បានលើកទ័ពមករុកកាន់រដ្ឋជលៀង (កំពែងពេជ្រ) ទៀត ។

កាលព្រះបាទសូរ្យវង្សទី ២ ដែលជាក្សត្រិយ៍សឹកបានឡើងសោយ រាជ្យហើយ ទ្រង់បានលើកទ័ពទៅក្រោមប្រទេសកៅដីប្រទេសចម្ប៉ា និងរដ្ឋលានណានេះ ឲ្យរាបទាប នៅក្រោមឥទ្ធិពលខ្មែរដូចដើមវិញ ដូចមានសំដែងហើយក្នុងព្រះរាជពង្សាវតារ ក្នុងរជ្ជកាលព្រះបាទសូរ្យ វង្សទី ២ស្រាប់ ។

## បែបបានទទួលស្គាល់ជាប្រទេសរាជ

កន្លងមកដល់ ព. ស. ១. ៨០០ ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ៨ នៃប្រទេសកម្ពុជា មានសេចក្តីប្រាកដនៅសិលាចារឹកក្រុងសុខោទ័យ ។

អំពីនេះ នឹងពណ៌នាទៅតាមន័យនៃសិលាចារឹកនោះ ក្នុងឆ្នាំ ព. ស. ១.៨០០ ព្រះមហាក្សត្រិយ៍ខ្មែរ (គឺព្រះបាទជយវរ្ម័នទី៨) ទ្រង់

បានស្ដាបនាក្សត្រិយ៍ថៃ ព្រះនាម "ផាមឿង" ថៃហៅថា ឃុនផាមឿង[១] ឲ្យគ្រងក្រុងសុខោទ័យ ក្នុងឋានៈជាប្រទេសរាជរបស់កម្ពុជា, ទ្រង់ព្រះរាជទាននាមថា "កម្រតេងអញស្រីឥន្ទ្របតិន្ទ្រាទិត្យ" (ហៅខ្លីថាស្រីឥន្ទ្រាទិត្យ) និង ព្រះរាជទានព្រះរាជធីតា ព្រះនាមព្រះនាងសិខរមហាទេវី ឲ្យជាមហេសីរបស់ឃុនផាមឿង ។

ឃុនផាមឿងនេះ ជាបុត្រឃុនស្រីណាវ ។ ឃុនផាមឿង គឺបុរសដែលខ្មែរហៅថាពញាពេជ, ថៃហៅ ព្រះរួង ។ កាលដែលតាំងឃុនផាមឿងជាស្ដេចត្រាញ់គ្រងក្រុងសុខោទ័យនោះ បានទ្រង់ព្រះមេត្ដាប្រោសឲ្យមន្ត្រីខ្មែរអ្នកធំ ឈ្មោះខ្លោញលំពង់ ដែលធ្លាប់គ្រប់គ្រងក្រុងសុខោទ័យមកមុននេះ នៅធ្វើរាជការអមព្រះស្រីឥន្ទ្របតិន្ទ្រាទិត្យផង ។

ការដែលព្រះបាទជយវរ្ម័នទី ៨ ទ្រង់ព្រះមេត្ដាប្រោសតាំងឃុនផាមឿងជាប្រទេសរាជត្រានេះ ដោយទ្រង់ឃើញថាជាតិថៃមកជ្រកនៅក្រោមព្រះបរមពោធិសម្ភារក៏ច្រើនសតវត្សហើយ, បំពោះរូបឃុនផាមឿងបានធ្វើជាមេគ្រប់គ្រងជាតិថៃដោយសេចក្ដីស្វាមីភក្ដិ មិនដែលមានផុលមោស, ព្រះរាជាទើបទ្រង់ព្រះមេត្ដាប្រោសតាំងជាស្ដេចត្រាញ់១ ក្នុងព្រះរាជអាណាចក្រ ។ ការតាំងត្រានេះជាហេតុឲ្យជាតិថៃបានឥស្សរភាពជាឯករាជ្យក្នុងអនាគតមិនយូរប៉ុន្មាន លុះមកដល់ប្រមាណ ព.ស. ១៨២០

---

១ ក្នុងសម័យសុខោទ័យ ថៃហៅស្ដេចផែនដី ថា ឃុន, មកដល់សម័យ ស្រីអយុធ្យាហៅថា ពញា ។

ឃុនរាមកំហែងជាទុរសព្រះស្រីឥន្ទ្រាទិត្យ (ពញាពេង) បានសោយរាជ្យនៅសុខោទ័យជារជ្ជកាលទី ៣ បានដកខ្លួនចេញពីអំណាចត្រួតត្រារបស់ខ្មែរស្រឡះ ឡើងជាឯករាជ្យពេញទី នៅក្នុងព្រះរាជអាណាចក្រខ្មែរ ។ ព្រោះក្នុងសម័យនោះ ជាតិថៃកំពុងប្រឹងប្រែងតស៊ូដើម្បីឯករាជ្យយ៉ាងខ្លាំង ៗ ចំណែកព្រះមហាក្សត្រិយ៍ខ្មែរ រាប់តាំងពីព្រះបាទជ័យវរ្ម័នទី ៨ មកចេះតែថយព្រះតេជានុភាពដោយលំដាប់ ៗ ព្រះចៅរាមកំហែងនេះជាអ្នកមានថ្វីដៃក្នុងការសង្គ្រាម ទើបអាចតាំងឯករាជ្យឡើងបាន ។ ថែមទាំងក្នុងសម័យនោះ មានក្សត្រិយ៍ថៃ ២ អង្គទៀត នៅយោនកជៀងសែនក៏បានផ្តើមតាំងសាងខ្លួនឡើងដែរ គឺមួយអង្គព្រះនាម "ព្រះចៅ ង៉ាំមឿង" តាំងរាជធានីនៅមឿងពយៅ (គឺស្រុកពយៅក្នុងកាលឥឡូវនេះ) ។ មួយអង្គទៀតព្រះនាម "ព្រះចៅ មេង៉រាយ" តាំងរាជធានីនៅមឿងឆើនយ៉ាង នៅខាងលើស្រុកជៀងសែនបន្តិច ។ រាប់ទាំងព្រះចៅរាមកំហែង រួមជា ៣ អង្គ ។ ស្តេចទាំង ៣ អង្គនេះជាមិត្រនឹងគ្នា ។

ក្នុងគ្រានោះ ប៉ែកខាងព្រះចៅមេង៉រាយរួបរួមរេហ៍ពលបានសមគួរហើយ ក៏លើកទៅតាំងរាជធានីថ្មី នៅជៀងរ៉ាយ កាលឃើញថា គ្មានអ្នកណាមករុករានបៀតបៀនទេ ក៏រួបរួមរេហ៍ពលជាថ្មីទៀត លើកកាត់ដែនព្រះចៅង៉ាំមឿងចុះមកខាងនិរតី មកបាននគរខេលាង្គនឹងនគរលំពូន (សឹងជាទីក្រុងចាស់ ដែលព្រះរាជទុរសរបស់ព្រះនាងចាមទេវី

ក្សត្រិយ៍ខ្មែរមានសាងទុកពីយូរមកហើយ) ដោយគ្មានអ្នកណាតស៊ូផង, កាលបាននគរទាំងពីរនេះក៏ប្រែរួមកង់ទ័ពបានចំនួនជាងមុន ហើយលើកមកវាយនគរហរិភុញ្ជ័យ ដែលក្នុងវេលានោះមានក្សត្រិយ៍ខ្មែរជាព្រះរាជវង្សខាងព្រះនាងចាមទេវី ព្រះនាមបាញ្ញារាជ នៅគ្រប់គ្រង ។ ព្រះអង្គបាញ្ញារាជ ប្រហែលជាមិនសូវមានឥទ្ធិពលនឹងគ្មានការតស៊ូឲ្យម៉ឺងម៉ាត់ទេ ទើបព្រះចៅមេងរ៉ាយយកព្រះនគរបាន ក្នុងគ្រានេះដោយស្រួល ។

ភូមិមណ្ឌលភាគពាយ័ព្យនេះ មានផ្ទៃផែនដីធំទូលាយ មានស្រុកជាច្រើនរហូតទៅដល់នគរជៀងម៉ៃ បានមកជាសម្បត្តិរបស់ខ្មែរតាំងពីពុទ្ធសករាជ ១.២០០ ។ កាលដំបូងនោះព្រះមហាក្សត្រិយ៍ខ្មែរបានទ្រង់តាំងព្រះនាងចាមទេវី ជាព្រះរាជធីតា នៃព្រះបាទចក្រពត្តិអ្នកគ្រប់គ្រងរដ្ឋទ្វារាវតីដែលតាំងរាជធានីនៅលពបុរី ឲ្យទៅគ្រប់គ្រងក្នុងឆ្នាំដូចមានខាងលើនេះ តាំងរាជធានីនៅនគរហរិភុញ្ជ័យឬហៅថាលំភូ ។ កាលព្រះនាងចាមទេវីទិវង្គតទៅហើយ ព្រះរាជវង្សរបស់ព្រះនាងបានគ្រប់គ្រងរដ្ឋហរិភុញ្ជ័យ តមកដល់រដ្ឋកាលព្រះអង្គបាញ្ញារាជ រួមជា ៥០ រដ្ឋកាល រួមវេលាជា ៦៣១ ឆ្នាំ ទើបបានធ្លាក់ទៅក្នុងកណ្ដាប់ដៃ ហើយលែងបានមកខ្មែរវិញពីគ្រានោះមក ។

ព្រះបាទជយវរ្ម័នទី ៨ នៅក្នុងរាជសម្បត្តិមកដល់ ព. ស. ១៨៣៨ ឬ ១៨៣៩ ក៏សោយទិវង្គត ។ គេថ្វាយព្រះនាមព្រះបរមសពដូចម្ដេចមិនប្រាកដ ។

(មានត)

# រឿងអារក្សថ្លែងរឿងម្ភៃប្រាំ

លោកសាង-សារ៉ាត លេខាធិការក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

ព្រះមហាក្សត្រទ្រង់យល់ព្រមតាមខាងលើនេះ រួចទ្រង់យកអារក្សនោះទៅជាមួយព្រះអង្គ ។ អារក្សនិយាយបន្ថែមទៀតថា: "បពិត្រព្រះមហាក្សត្រ! មនុស្សចេះដឹង មានប្រាជ្ញាឈ្លាសវៃ រាល់ថ្ងៃតែងតែសោយនូវតម្រេកនៃចម្រៀង នឹងការសិក្សា, ការអានសៀវភៅធម៌ ៗ ឯពួកសត្វតិរច្ឆាននឹងពួកកំជិល រាល់ថ្ងៃតែងតែដេកលេងសប្បាយឥតប្រយោជន៍ ៗ ក្នុងដំណើរនេះ ត្រូវតែព្រះអង្គនឹងទូលបង្គំពិភាក្សាគ្នាអំពីធម៌ដែលមានប្រយោជន៍, ទូលព្រះបង្គំនឹងនិទានរឿងថ្វាយ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ ដូចខាងក្រោមនេះ" ។

## រឿងទី ១

ស្ដេចស្រុកពេណារេស (Bénarès) ព្រះនាមប្រាតាប-មុកាត (Pratâp-Mukat) មានអគ្គមហេសីព្រះនាមមហាទេវី (Mohâdévi) មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមពជី-មុកាត (Baji-Mukat) ។ ថ្ងៃមួយ ព្រះអង្គម្ចាស់នោះ បានយាងទៅបរបាញ់សត្វជាមួយកូនប្រុសរបស់នាយករដ្ឋមន្ត្រី (រដ្ឋមន្ត្រីទី ១) ហើយស្ដេចយាងរុកចូលទៅក្នុងព្រៃជ្រៅ ៗ មួយស្របក់

ទៅទៀត ស្ដេចបានយាងទៅដល់ត្រពាំងទឹក ១ ល្អអស្ចារ្យ ៗ នៅលើមាត់ត្រពាំងនោះ មានសត្វក្ងាន, ប្រវឹក, មាន់ទឹក, ទាញី, ទាឈ្មោល នូវសត្វក្រួចទឹងសត្វគ្រប់យ៉ាង កំពុងតែទទះស្លាបលេង ៗ នៅជ្រុងទាំង ៤ មានទៀនធ្វើអំពីឥដ្ឋលេចឡើងយ៉ាងប្រច័ក្ស ៗ ផ្កាឈូករីករហង់នៅក្នុងគង្គា ៗ ដំនោរត្រជាក់ បក់តាមម្លប់ព្រឹក្សានានា ដែលដុះនៅទីនោះ ៗ បក្សីទាំងឡាយ យំកញ្ជ្រៀវលេងសប្បាយតាមមែកព្រឹក្សា ៗ បុប្ផាគ្រប់បែបប្រកបដោយក្លិនទឹងពណ៌ស្រស់ប្រិមប្រិយ មានហ្វូងឃ្មុំរំពឹកគុះគរក្រេបលំអងផ្កាពាសពេញព្រៃ ៗ គ្រានោះ ព្រះអង្គម្ចាស់ទឹងមិត្ររបស់ទ្រង់ ក៏បុះតម្រង់ទៅមាត់បឹង ដើម្បីលុបលាងព្រះហស្តទឹងលុបលាងហត្ថា ៗ លុះឡើងមកវិញ ជនទាំងពីរ បានដើរតម្រង់ឆ្ពោះទៅកាន់គ្រឹហារបស់មហាទេវី ដោយបានបង់សេះបញ្ឈប់ទុកឲ្យដឹកខាងក្រៅ រួចទើបចូលទៅក្នុងគ្រឹហានោះ, លុះថ្វាយដង្វាយរួចជាស្រេច ក៏ចេញមកក្រៅវិញភ្លាម ៗ ក្នុងពេលដែលទ្រង់កំពុងស្ងួតធម៌ ស្រាប់តែបុត្រីមួយព្រះអង្គរបស់ស្តេច បានយាងមកលេងនៅទីមាត់បឹងនោះជាមួយស្រីស្នំជាច្រើន ដើម្បីលុបលាងអង្គកាយផង ដើម្បីបំពេញករណីយកិច្ចខាងសាលាផង ៗ លុះព្រះនាងបានលុបលាងព្រះកាយទឹងសម្រួមចិត្តគំនិតបន់ស្រន់រួចស្រេច ព្រះនាងក៏យាងក្រសាលសប្បាយក្រោមម្លប់ឈើជាមួយស្រីស្នំទាំងនោះ ៗ

ក្នុងពេលនោះ កូនរដ្ឋមន្ត្រីនៅអង្គុយស្ងៀម, ឯព្រះអង្គម្ចាស់ស្តេចយាងចុះឡើងៗ ស្រាប់តែព្រះនេត្ររបស់ទ្រង់ ជួបប្រទះគ្នានឹងព្រះនេត្ររបស់ព្រះនាងខត្តិយា ។ ព្រះអង្គម្ចាស់ទ្រង់ស្ទុកព្រះស្មារតី ហើយទ្រង់ត្អូញថា: "ឱកាម! (Kâma) ម្ដេចក៏អ្នកធ្វើឲ្យខ្ញុំវេទនាដូច្នេះ" ។

ឯព្រះនាងក្សត្រី លុះឃើញព្រះអង្គម្ចាស់នោះហើយ ព្រះនាងក៏ហូតយកផ្កាឈូកដែលដាក់លើព្រះកេសា ទៅសៀតត្រង់ព្រះកាណ៌វិញ រួចយកមកខាំនឹងព្រះទន្តហើយទើបដាន់បោលទៅ ។ ក្រោយមក ព្រះនាងបានរើសយកមកវិញ ហើយយកទៅដាក់លើដើមទ្រូងព្រះនាង ។ លុះធ្វើដូច្នោះហើយ ទើបព្រះនាងយាងត្រឡប់ទៅទីស្ថានវិញ ព្រមទាំងស្រីស្នំទាំងអស់ផង ។ ចំណែកខាងព្រះអង្គម្ចាស់ ដោយទ្រង់អស់សេចក្ដីសង្ឃឹមតទៅទៀត ទើបនាំឲ្យទ្រង់មានទុក្ខជាទម្ងន់ព្រោះការឃ្លាតឃ្លានេះ ហើយស្ដេចយាងទៅជិតកូនលោករដ្ឋមន្ត្រី ទ្រង់សារស័ព្ទប្រាប់អំពីរឿងដែលកើតឡើងនោះដូចមានតទៅនេះ: "នែសម្លាញ់! ខ្ញុំឃើញនារីម្នាក់ល្អស្អាត, ខ្ញុំមិនបានស្គាល់ឈ្មោះនឹងទីលំនៅរបស់គេទេ ប៉ុន្តែខ្ញុំស្រឡាញ់គេឥតអ្វីប្រៀបបាន ហើយបើប្រសិនជាខ្ញុំមិនបាននាងនោះធ្វើជាកិរិយាទេ ជីវិតខ្ញុំមុខជាមិនរស់ឡើយ" ។

កូនលោករដ្ឋមន្ត្រីលុះដឹងរឿងនេះ ហើយក៏នាំព្រះអង្គម្ចាស់ឲ្យគង់លើសេះហើយនាំស្ដេចវិលត្រឡប់ចូលប្រាសាទវិញ ប៉ុន្តែទុក្ខព្រួយព្រោះ

ការឃ្លាតឆ្ងាយ បានធ្វើឲ្យទ្រង់ទ្រុឌទ្រោមយ៉ាងខ្លាំង នាំឲ្យទ្រង់គង់នៅស្ងៀមឥតសរសេរ ឥតមើលសៀវភៅ ឥតផ្ទំ ឥតសោយទឹកនឹងអាហារអ្វីសោះ, ទ្រង់ចោលកិច្ចការផែនដីគ្មានសល់កន្លែងណា ។ ព្រះអង្គម្ចាស់បានគូររូបនាងរូបទ្រង់គង់មើល ដោយមានទឹកព្រះនេត្រហូររហាម, ពុំមានព្រះឱង្ការសូម្បីតែមួយម៉ាត់ ព្រមទាំងទ្រង់លែងព្រះសណ្ដាប់អ្វីទាំងអស់ ។

កូនលោករដ្ឋមន្ត្រី កាលណាឃើញព្រះអង្គទ្រង់គង់ក្នុងឋានៈនៃសេចក្ដីឃ្លាតឃ្លាសង្កត់សង្កិនដូច្នោះ ក៏ទូលថា “ជនណាយកជើងជាន់លើផ្លូវស្នេហា ជននោះមិនបានឈ្មោះថាមានជីវិតរស់នៅទេ, តែទោះបីជននោះរស់នៅក៏ដោយ ក៏គង់មានទុក្ខធំបំផុតពុំខានឡើយ” ។

ព្រះអង្គម្ចាស់លុះទ្រង់ព្រះសណ្ដាប់ពាក្យដូច្នោះ ក៏មានព្រះរាជឱង្ការតបវិញថា: “ថ្វីបើខ្ញុំដើរតាមផ្លូវនោះ ឲ្យតែខ្ញុំអាចរកសេចក្ដីសប្បាយឃើញ ក៏ទុកដូចជាខ្ញុំរកសេចក្ដីទុក្ខឃើញដែរ” ។

កូនលោករដ្ឋមន្ត្រីទូលទៀតថា “ឱព្រះអង្គម្ចាស់! កាលព្រះនាងចេញអំពីព្រះអង្គទៅ តើព្រះនាងមានព្រះបន្ទូលអ្វីខ្លះនឹងព្រះអង្គឬទេ? ទាំងព្រះអង្គវិញសោត តើទ្រង់មានព្រះបន្ទូលអ្វីខ្លះទៅរកព្រះនាងដែរ?” ។

ព្រះអង្គម្ចាស់ឆ្លើយថា “ទេ! ខ្ញុំឥតនិយាយអ្វីនឹងនាងទេ ឯរូបនាងក៏ឥតនិយាយអ្វីនឹងខ្ញុំដែរ” ។

កូនលោករដ្ឋមន្ត្រីទូលថា "បើដូច្នោះ ពិបាកនឹងជួបព្រះនាងណាស់" ។

ព្រះអង្គម្ចាស់មានព្រះបន្ទូលថា "បើប្រសិនណាជាខ្ញុំឃើញនាង ខ្ញុំអាចរស់នៅតទៅទៀតបាន, បើមិនឃើញទេ ជីវិតខ្ញុំមុខជារលត់ពុំខាន" ។

កូនលោករដ្ឋមន្ត្រីសួរថា "តើព្រះនាងគ្មានធ្វើសញ្ញាអ្វីមួយទេឬ!"

ព្រះអង្គម្ចាស់ឆ្លើយថា: "កាលនាងឃើញខ្ញុំ នាងហូតផ្កាឈូកពីក្បាលយកទៅដាក់នឹងត្រចៀក រួចនាងខាំនឹងធ្មេញ ហើយយកទៅដាន់នឹងជើង, ទីបំផុត នាងយកផ្កានោះទៅដាក់លើដើមទ្រូងវិញ" ។

កូនលោករដ្ឋមន្ត្រីនិយាយថា "បើដូច្នោះ ទូលព្រះបង្គំយល់សញ្ញាអស់នោះហើយ, ឥឡូវនេះ ទូលព្រះបង្គំស្គាល់ព្រះនាមនឹងទីលំនៅរបស់ព្រះនាងជាប្រាកដ" ។

ព្រះអង្គម្ចាស់មានព្រះបន្ទូលថា "បើដូច្នោះ ចូរមិត្រអាណិតប្រាប់ខ្ញុំផង" ។ បុរសក៏ចាប់ផ្ដើមទូលរឿងនោះ ដូច្នេះថា: "សូមស្ដេចទ្រង់ព្រះសណ្ដាប់! កាលដែលព្រះនាងហូតផ្កាឈូកអំពីព្រះសិរ ហើយយកទៅសៀតនៅត្រចៀកវិញ នោះព្រះនាងចង់ប្រាប់ថា "ខ្ញុំជាអ្នកស្រុកបនិតិប (Cornatic), កាលដែលព្រះនាងយកផ្កាឈូកទៅខាំនឹងធ្មេញ ព្រះនាងចង់ទូលព្រះអង្គថា "ខ្ញុំជាបុត្រីស្ដេចទន្ត-ពត (Dan-bat) (ទ្រព្យដែលមានក្បាច់ដូចធ្មេញ)", កាលដែលព្រះនាងយកផ្កាទៅដាន់នឹងជើង

ព្រះនាងបង្គំទូលព្រះអង្គថា "ខ្ញុំឈ្មោះបទុមវតី (Padmavati) អ្នកស្រឡាញ់ផ្កាឈូក)", កាលដែលព្រះនាងយកផ្កាទៅដាក់លើដើមទ្រូងនោះ គឺព្រះនាងបង្គំទូលព្រះអង្គថា "ព្រះនាងត្រូវចិត្តនឹងព្រះអង្គណាស់" ។

លុះនិយាយដូច្នោះរួច ជនទាំងពីរនាក់ក៏ស្លៀកពាក់ដាក់គ្រឿងអាវុធ និងយកមាសពេជ្របន្តិចបន្តួចទៅជាប់ផង ហើយនាំគ្នាឡើងជិះសេះទៅសំដៅស្រុកដែលនាងនៅ ។ កាលកន្លងច្រើនថ្ងៃមក ទើបបានទៅដល់ស្រុកបទិតិប កាត់តម្រង់ទៅរកទីក្រុង ទើបបានទៅដល់កំពង់ស្តេច ហើយបានប្រទះនឹងយាយចាស់ម្នាក់ ដែលកំពុងអង្គុយរវៃអម្បោះនៅមាត់ទ្វារ ។ ជនទាំងពីរក៏ចុះពីលើខ្នងសេះ ចូលទៅជិតយាយនោះ ហើយនិយាយថា: "នុអ្នកម្ដាយអើយ ! យើងខ្ញុំនេះជាអ្នកដំណើរ ហើយជាឈ្មួញផង ។ ឯទ្រព្យរបស់ដែលយើងខ្ញុំជួញនោះ មកតាមក្រោយឯណោះ ប៉ុន្តែយើងខ្ញុំមកមុនដើម្បីរកកន្លែងនៅសំណាក់អាស្រ័យ ។ ហេតុដូច្នេះ សូមលោកម្ដាយមេត្តាប្រាប់កន្លែងណាមួយ ដែលយើងខ្ញុំអាចនៅបានផង" ។

កាលយាយចាស់បានឮសំដីដូច្នោះ ទើបសំឡឹងមើលមុខជនទាំងពីរ ហើយនិយាយថា: "ផ្ទះនេះគឺជាផ្ទះរបស់អ្នកហើយ, អ្នកអាចនៅយូរបានតាមចិត្ត" ។

និមិត្តតែឮពាក្យដូច្នោះ ជនទាំងពីរក៏ចូលទៅនៅក្នុងផ្ទះនោះទៅ, លុះមួយស្របក់ក្រោយមក យាយចាស់ក៏ទៅអង្គុយជិត ហើយនិយាយលេង

ជាមួយយ៉ាងស្និទ្ធស្នាល ។ ឯកូនលោកវេជ្ជបណ្ឌិតបានសាកសួរអំពីកូនចៅក្រុមគ្រួសាររបស់យាយនោះ ទឹងអំពីផលរបរដែលគាត់រកចិញ្ចឹមជីវិត ។

- នុចៅ! កូនប្រុសរបស់ខ្ញុំដែលនៅបំរើស្ដេច ជាអ្នកមានមុខងារប្រសើរណាស់, ឯព្រះនាងបទុវតី ជាកជបុត្រីបានចៅដោះខ្ញុំ ។ ឥឡូវនេះ ខ្ញុំចាស់ហើយ, ដែលខ្ញុំនៅក្នុងផ្ទះនេះ គឺដោយព្រះករុណាជាម្ចាស់ជីវិតស្ដេចទ្រង់គ្រប់គ្រងចិញ្ចឹមខ្ញុំ ។ រាល់ថ្ងៃខ្ញុំតែងតែទៅមើលរក្សាព្រះនាង ប៉ុន្តែក្នុងពេលដែលខ្ញុំត្រឡប់មកវិញ ចិត្តរបស់ខ្ញុំព្រួយខ្លាំងណាស់ ។

លុះឮដូច្នោះ ព្រះអង្គម្ចាស់មានព្រះហឫទ័យរីករាយ ហើយទ្រង់មានព្រះបន្ទូលទៅកាន់យាយនោះថា: "ដល់ថ្ងៃស្អែក, ក្នុងពេលដែលយាយអញ្ជើញទៅមើលនាង តើយាយហ៊ានទទួលសាររបស់ខ្ញុំមួយឬទេ?" ។

យាយចាស់ឆ្លើយតបថា: "ម្ដេចក៏អ្នកថាចាំដល់ថ្ងៃស្អែក? តោះអ្នកនិយាយយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចយកសាររបស់អ្នកទៅឲ្យនាងឥឡូវនេះបានដែរ" ។

ព្រះអង្គម្ចាស់តបទៅវិញថា: "បើដូច្នោះ ចូរលោកយាយទៅទូលព្រះនាងថា: "ស្ដេចដែលព្រះនាងឃើញនៅមាត់ត្រពាំងពីថ្ងៃ ៥ កេចខែមិថុនា (Jèth) នោះ ឥឡូវនេះទ្រង់យាងមកដល់ហើយ" ។

យាយចាស់បានទទួលបង្គាប់នោះ រួចក៏កាន់ឈើច្រត់ដើរចូលទៅក្នុងព្រះបរមរាជវាំង, ឃើញព្រះនាងគង់នៅម្នាក់ឯង, កាលគាត់ទៅ

ដល់មុខព្រះនាងហើយ ព្រះនាងក៏គំនាប់គាត់ៗ ក៏បានឲ្យពរសព្ទសាធុការដល់ព្រះនាង រួចនិយាយថា: "នែកូនស្រីសំឡាញ់! កាលនាងនៅតូច ខ្ញុំបានបំរើនាង, បំបៅដោះនាង! ឥឡូវនេះ ដោយគុណបុណ្យព្រះ នាងធំឡើង, ខ្លួនខ្ញុំមុខជាបានសប្បាយចិត្តដោយសារនាងពុំខាន បើប្រសិនណាជាយុវជនរបស់នាងប្រកបដោយសុខសួស្តី" លុះចប់ពាក្យជំអូញនោះហើយ ទើបគាត់និយាយទៀតថា: "ព្រះអង្គម្ចាស់ ដែលនាងចាប់ចិត្តជាប់កាលពីថ្ងៃ ៥ កេច ខែមិថុនានៅមាត់ត្រពាំង ឥឡូវនេះស្តេចបានឲ្យខ្ញុំនាំសារមកប្រាប់នាងថា: "បងមកដល់ហើយ សូមប្អូនបំពេញកិច្ច ដែលនាងបានសន្យានឹងព្រះអង្គម្ចាស់នោះក្នុងពេលនេះ", ចំណែកខ្ញុំវិញ ខ្ញុំសូមនិយាយនឹងនាងថា: "ដោយពិតទៅ ស្តេចនោះត្រូវជាគូនឹងនាងហើយ, គេល្អដូចនាងដែរ ហើយមានសន្តចរិយាគ្រប់បែបផង" ។

ដោយទ្រង់ខ្មាសជាខ្លាំង, កាលឮពាក្យនោះហើយ ព្រះនាងក៏យកឈើក្រអូប ១ ដុំវាយយាយនោះ រួចស្រែកថា: "ចេញអំពីជំណាក់យើងឲ្យឆាប់ យាយចាស់អប្រិយ!" ។

ឯយាយចាស់នោះ អាក់អន់ចិត្តជាខ្លាំងទើបចូលទៅរកព្រះអង្គម្ចាស់ ហើយនិទានរឿងអាក្រក់នោះប្រាប់ដោយសព្វគ្រប់ ។ ព្រះអង្គម្ចាស់ក៏ភិតភ័យជាខ្លាំង ប៉ុន្តែកូនលោករដ្ឋមន្ត្រីក្រាបទូលថា: "សូមទ្រង់កុំគិតដល់រឿងនោះឲ្យសោះ ព្រោះទ្រង់យល់មិនទាន់ដល់ទេ" ។

ព្រះអង្គម្ចាស់តបវិញថា: បើដូច្នោះ ចូរមិត្រពន្យល់ខ្ញុំផង, ចូរមិត្រធ្វើឲ្យបញ្ញារបស់ខ្ញុំបានស្មៀមស្រួលផង" ។

– កាលនាងយកម្រាមដៃទាំង ១០ ដាប់ដុំឈើក្រអូបហើយវាយចំមុខយាយនោះ នាងចង់ពន្យល់ថា: "កូនរាំងដប់ថ្ងៃទៅមុខទៀត ព្រះអង្គម្ចាស់នឹងនាងត្រូវទៅជួបគ្នាកណ្ដាលរាត្រីងងឹត ។

លុះបាន ១០ ថ្ងៃហើយ យាយចាស់ទៅថ្វាយដំណឹងអំពីព្រះអង្គម្ចាស់ប្រាប់ព្រះនាង ។ ឯនារីបានយកម្រាមដៃ ៣ ផ្ទាត់យាយចាស់ហើយនិយាយថា: "ចេញអំពីដំណាក់យើងទៅ!" ។

ដោយមិនដឹងធ្វើអ្វី យាយចាស់ក៏ចេញមកវិញ ហើយទៅនិទានរឿងនោះទូលព្រះអង្គម្ចាស់ ។ ព្រះអង្គម្ចាស់មានព្រះទ័យរឹងរឹតតែព្រួយព្រោះបានឮពាក្យរបស់យាយ ។ កូនលោករដ្ឋមន្ត្រី កាលបានឃើញដូច្នោះ ក្រាបទូលព្រះអង្គម្ចាស់ថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះអង្គកុំព្រួយ, ន័យរបស់រឿងនេះ ពិតជាផ្សេងស្រឡះ អំពីព្រះតម្រិះរបស់ព្រះអង្គ" ។

ព្រះរាជាមានព្រះបន្ទូលថា: "សូមមិត្រនិយាយឲ្យឆាប់ទៅមើល! ព្រោះសញ្ញារបស់ខ្ញុំប្រាម្ភខ្លាំងណាស់" ។ កូនលោករដ្ឋមន្ត្រីនិយាយថា: "នាងនៅក្នុងឋានៈជមូតានៃស្ត្រី, ដោយហេតុនេះហើយ នាងនឹងត្រូវធ្វើតាមកិច្ចសន្យារបស់នាងក្នុងរវាង ៣ ថ្ងៃទៀត សូមព្រះអង្គរង់ចាំដល់ថ្ងៃទី ៤ សិន" ។

លុះបាន ៣ ថ្ងៃក្រោយមក យាយចាស់ក៏ទៅយកដំណឹងសុខ-ទុក្ខ អំពីព្រះនាងកល្យាណីក្សត្រី ។ ប៉ុន្តែព្រះនាងទ្រង់ខ្ញាល់ បាននាំយាយចាស់នោះសំដៅទៅមាត់ទ្វារខាងថ្ងៃលិច ហើយបានប្រាប់គាត់ឲ្យចេញទៅខាងក្រៅ ។ យាយចាស់ត្រឡប់មកវិញ បានអធិប្បាយរឿងនោះទូលព្រះអង្គម្ចាស់ ដែលកំពុងមានព្រះទ័យព្រួយពន់ពេក ។ ប៉ុន្តែកូនលោករដ្ឋមន្ត្រីនិយាយទៀតថា : "ឯរឿងនោះដូច្នេះទេ : ស្អែក, នៅវេលាយប់ គេនឹងឲ្យព្រះអង្គម្ចាស់យាងទៅត្រង់មាត់ទ្វារនោះឯង" ។ និមិត្តតែឮពាក្យនោះ ព្រះអង្គម្ចាស់ទ្រង់រីករាយជាពន់ពេក ។

កាលដល់កំណត់ពេលហើយ ជនទាំងពីរនាក់បានស្លៀកខ្មៅពាក់ខ្មៅ ជួតក្បាលស្រួលបួលជាស្រេច ហើយបង្គៀងអាវុធគប់គ្រាន់រៀង ៗ ខ្លួន ។ គ្រាន់តែរៀបចំរួច រយៈពេលម៉ោង ៣ គត់ក៏ប្រុកដមក ។ សោតឯពេលនោះជាពេលស្ងប់ស្ងាត់ណាស់ ។ ជនទាំងពីរនាក់ចេញទៅយ៉ាងស្ងៀមស្ងាត់ឥតនិយាយគ្នាឡើយ ។ លុះទៅដល់ជិតមាត់ទ្វារហើយ កូនលោករដ្ឋមន្ត្រីក៏នៅខាងក្រៅ ព្រះអង្គម្ចាស់យាងចូលទៅតែមួយព្រះអង្គឯង ទ្រង់ឃើញព្រះនាងកំពុងតែឈរចាំព្រះអង្គ ។ កាលណានេត្រាទាំងពីរព្រះអង្គជួបគ្នាហើយ ព្រះនាងខត្តិយានីក៏ទ្រង់ញញឹម ហើយបិទទ្វារ រួចទើបនាំព្រះបេស្កាចូលទៅក្នុងបន្ទប់មួយ ដែលព្រះនាងបានរៀបចំរួច ទុកសម្រាប់ជាទីតម្រេកដោយកាមតណ្ហា ។

(មានត)

# ដំណើរមកកាន់ប្រទេសកម្ពុជា

# នៃមហាបណ្ឌិតគុណបាលបិយសេន ម៉ាឡ៉ាល៉ះសេកេរៈ

## ជាអធិបតីពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

## របស់ពុទ្ធសាសនបណ្ឌិត្យ

(ត កម)

ក្នុងពេលដែលខ្ញុំមកកាន់ប្រទេសខ្មែរនេះ ខ្ញុំឃើញជនជាតិខ្មែរមានសន្តានល្អជាបំផុត ព្រោះខ្ញុំទៅកន្លែងណា ក៏គេចេះតែមានទឹកមុខញញឹមទទួលខ្ញុំជានិច្ច ៗ ដូច្នេះ បើលោកអ្នកមានឱកាស សូមអញ្ជើញទៅលេងស្រុកខ្ញុំម្តង ខ្ញុំនឹងទទួលវិញ ដោយរាក់ទាក់យ៉ាងនេះដែរ ៗ

ក្នុងទីបំផុតសេចក្តីនេះ ខ្ញុំសូមគោរពយ៉ាងខ្ពង់ខ្ពស់ ចំពោះព្រះមហាក្សត្រ ហើយសូមប្រសិទ្ធិពរដើម្បីព្រះអង្គបានប្រកបដោយសេចក្តីសុខក្នុងសិរីរាជសម្បត្តិជាអង្វែងតទៅ, មួយទៀតសូមសំដែងសេចក្តីគោរពចំពោះរាជរដ្ឋាភិបាលនិងបណ្តាជនទាំងឡាយ ដែលបានជូនសេចក្តីរាប់អានយ៉ាងខ្ពង់ខ្ពស់ដល់ខ្ញុំ ៗ

កាលលោកម៉ាឡ៉ាល៉ះសេកេរៈ ថ្លែងសន្និសីទនេះចប់ហើយ សម្តេចព្រះមហាសុមេធាធិបតី ក៏ប្រកាសសុំឲ្យព្រះសង្ឃទាំងឡាយសូត្របូជាវិសាខ នៅម៉ោង ៨ ព្រឹកនៃថ្ងៃ ១ កេចខែវិសាខ គឺជាថ្ងៃដែលមហាសន្និបាត ពុទ្ធសាសនាបានកំណត់ ព្រោះព្រះសម្ពុទ្ធទ្រង់ចូលនិព្វានទៅ

ពេលបែកបច្ចូសពេញបូណ៌មីខែវិសាខ គឺជិតភ្លឺនៃថ្ងៃ ១ រោចខែនេះឯង ប៉ុន្តែត្រូវរៀបគ្រឿងសក្ការៈ ធ្វើពិធីផ្សេងៗ តាមទំនៀមតាំងពីថ្ងៃទី ១៥ ទៅ ហើយនៅពេលសូត្របូជារួច សូមឲ្យនាំគ្នាពឹងផ្សាយមេត្តាចិត្ត ចំនួន ២ នាទីថា "សូមឲ្យពិភពលោកទាំងមូលបានសេចក្ដីសុខទៅ" ។

ការផ្សាយមេត្តាចិត្តនេះ ជាពិធីមួយដែលប្រទេសកាន់ពុទ្ធសាសនាទាំង ៦៤ ស្រុះគ្នាធ្វើក្នុងពេលតែមួយដូចគ្នា ដើម្បីឲ្យកម្លាំងចិត្តអាចនឹងគ្របដណ្ដប់អសន្តិសុខបាន ។

សម្ដេចបានមានថេរដីកាបញ្ជាក់ទៀតថា នៅវត្តឧណ្ណាលោម ខ្ញុំនឹងបាត់ថែងធ្វើវិសាខបូជានេះ ២ ថ្ងៃ គឺតាំងពីយប់ថ្ងៃ ១៥ កើតទៅយប់ថ្ងៃ ១ រោច ។

## បុណ្យសម្ពោធខឿនព្រះពោធិព្រឹក្ស

ព្រះពោធិព្រឹក្សដែលប្រតិស្ឋាននៅមុខសាលាបាលីជាន់ខ្ពស់ភ្នំពេញនោះជាកេរ្តិ៍នៃព្រះនារទត្ថេរ លោកបាននាំពីលង្កាទ្វីបមកជូនពុទ្ធសាសនបណ្ឌិត្យ ក្នុងឆ្នាំ ព.ស. ២៤៨១ រជ្ជកាលព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្ស ។ ដល់មកក្នុងឆ្នាំ ព.ស. ២៤៩៤ នេះ មានពុទ្ធបរិស័ទច្រើននាក់ផ្ដើមកសាងខឿន ធ្វើពីស៊ីម៉ងត៍ទីងតដ្ឋវិចិត្រដោយក្បាច់របនាគួររមិលមើល ។ ឯនាមអ្នកផ្ដើមសាងនោះគឺ លោកជ័យ-មៀច អ្នកស្រីមុជ, លោកពុត-អ៊ុម អ្នកស្រីសន, លោកស្រី-ធិន អ្នកស្រីយ៉ា,

នឹងលោកក្រុមប្រឹក្សាសុខ-ខៃ ។ នាមនៃលោក អ្នកទាំងនោះ សឹង មានបារីកទុកភ្ជាប់នៅខឿនព្រះពោធិព្រឹក្ស ផ្ទុំនាង៍កើតបំប្រាប់ ។

កាលពីថ្ងៃទី ២០ ខែធុសភាឆ្នាំ ១៩៥១ ពេលម៉ោង ៤ កន្លះ រសៀល ពុទ្ធបរិស័ទ្យបានរៀបពិធីសម្ពោធខឿនព្រះពោធិព្រឹក្សនោះ ។ ក្នុងពិធីនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ស្តេចយាងមក ជាព្រះរាជាធិបតី ។ មានទាហានក្រុមរក្សាព្រះអង្គនឹងក្រុមភ្លេងនៃ ទាហាននេះចាំធ្វើគារវកិច្ចតាមទំនៀម ។ ឯកឧត្តម អ៊ុំ-ឈាងស៊ុនជា នាយករដ្ឋមន្ត្រី នឹងឯកឧត្តមសម-ញាណ ជារដ្ឋមន្ត្រីក្រសួងធម្មការ បានអញ្ជើញទៅចាំក្រាបបង្គំគាល់ព្រះរាជា ជាមួយនឹងឥស្សរជនដទៃ ទៀតជាច្រើន ។

លុះជួបជុំគ្នាហើយ សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ជាសង្ឃនាយក បានថ្វាយអំពីប្រវត្តិនៃព្រះពោធិព្រឹក្សនេះ ព្រមទាំងបាន ថ្វាយអំណរយ៉ាងក្រៃលែង ក្នុងនាមនៃពុទ្ធបរិស័ទ្យជាអ្នកបាត់ចែងបុណ្យ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់បានព្រះរាជទាន កិត្តិយសដ៏ខ្ពង់ខ្ពស់ដល់ពិធីនេះ ។

នៅទីបំផុត សម្តេចបានប្រសិទ្ធិពរក្នុងនាមនៃពុទ្ធបរិស័ទ្យទាំងអស់ ថ្វាយចំពោះព្រះមហាក្សត្រ, ចំពោះព្រះបរមរាជបិតា, ចំពោះព្រះបរម- ជននីនាថ នឹងចំពោះព្រះរាជវង្សានុវង្សទាំងឡាយ ។

បន្ទាប់មក មហាបណ្ឌិត ម៉ាល៉ាល៉ាសេកេរៈ បានថ្លែងសុន្ទរកថាសង្ខេប ដែលឥតព្រាងមួយ ជាភាសាអង់គ្លេសទៅចំពោះព្រះភក្ត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដោយមានលោក កេម៉ង់-ប៉ាន់ ជាអ្នកបកប្រែជាខ្មែរ មានសេចក្ដីដូចយើងសរសេរសម្រួលជូនមើល តទៅនេះ:-

សូមព្រះតេជះជំកល់លើត្បូង,

សូមព្រះរាជទានក្រាបបង្គំទូល ព្រះករុណាជាអម្ចាស់ជីវិត សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ !

ទូលព្រះបង្គំជាខ្ញុំ មានបំណងនឹងមកកាន់ប្រទេសខ្មែរជាយូរហើយ តែទើបនឹងបានសម្រេចបំណងនោះក្នុងពេលនេះ ដោយសារត្រូវបំពេញបេសកកម្មខាងពុទ្ធសាសនា ។ ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីត្រេកអរជាទីបំផុត ចំពោះសំណាងទូលព្រះបង្គំ ដែលបានមកចួបនឹងពិធីបុណ្យដ៏ឧឡារិកនេះ ដែលមានទាំងការដង្ហែខឿនព្រះពោធិព្រឹក្ស ទាំងពិធីវិសាខបូជា ជាបុណ្យដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងបានប្រោសព្រះរាជទានកិត្តិយស ដោយទ្រង់ស្ដេចមកជាព្រះរាជាធិបតី ។

ដើមពោធិព្រឹក្សនេះ ប្រាកដជាមានពូជជាមកពីពោធិព្រឹក្សបុរាណដែលជាទីត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធ ហើយដែលពុទ្ធបរិស័ទទាំងឡាយគោរពរាប់អានគ្រប់ប្រទេស ដរាបដល់សព្វថ្ងៃនេះ ។ តាមប្រវត្តិសាស្ត្រថា: ក្នុងពេលដែលព្រះសាស្ដាបរិនិព្វានទៅបាន ២៣៦ ឆ្នាំ ព្រះសង្ឃ

មិត្តាថេរី ដែលជាព្រះរាជបុត្រីនៃព្រះបាទអសោក បានសាកយកមែកនៅទិសខាងត្បូងនៃពោធិព្រឹក្សចាស់នោះ ទៅប្រតិស្ឋាននៅក្រុងអនុរាធបុរៈ ក្នុងរាជ្យព្រះបាទទេវានម្បិយតិស្ស ។ កន្លងកាលមកបន្តិច ពោធិចាស់ដែលនៅឥណ្ឌានោះក៏វិនាសទៅ ដោយត្រូវពួកកាន់សាសនាដទៃបំផ្លាញ ។ ដូច្នេះ ប្រជាជនលង្កា ក៏មានសេចក្តីត្រេកអរណាស់ដោយឃើញថាមានតែប្រទេសខ្លួនមួយប៉ុណ្ណោះទេ ដែលមានសំណាងបានរក្សាពូជព្រះពោធិព្រឹក្សចាស់នោះឲ្យគង់វង្ស ហើយដែលអាចបំបែកពូជជាទៅប្រតិស្ឋាននៅនានាប្រទេសទៀតបាន ។ មានប្រទេសជាច្រើនបានទៅចំឡងយកពូជពោធិព្រឹក្សនេះ ។

បពិត្រព្រះសម្មតិទេវវង្ស ! ព្រះពោធិព្រឹក្សនៅលង្កានោះ មានអាយុជាង ២ ០០០ ឆ្នាំហើយ, អ្នកស្រុកលង្កាធ្វើសក្ការៈគោរពដើមពោធិ៍នោះជាទីបំផុត ។ កាលពីឆ្នាំមុន មានគេយករបស់មិនស្អាតទៅចងព្យួរនៅដើមពោធិព្រឹក្ស ដែលជាហេតុនាំឲ្យព្រះពោធិ៍នោះសៅហ្មង, អស់កាលមិនយូរប៉ុន្មាន ហេតុភេទមិនស្រួលផ្សេងៗ ក៏បណ្តាលកើតមានឡើងក្នុងប្រទេសលង្កា ។ ទូលព្រះបង្គំជាខ្ញុំជឿថា បើដើមពោធិព្រឹក្សនេះ មានជីវភាពនៅដរាបណា សាសនារបស់ព្រះសម្មាសម្ពុទ្ធ ក៏មាននៅដរាបនោះដែរ ។ តាមព្រះពុទ្ធតំរាស់ដែលបានផ្តាំទុកមកថាៈ រូបកាយនៃដើមពោធិ៍នេះ ក៏ទុកដូចជារូបកាយនៃមនុស្សដែរ ព្រោះអាចជា

តំណាងអង្គនៃព្រះអង្គបាទ សំរាប់ឲ្យពួកពុទ្ធបរិសទ្យធ្វើសក្ការបូជាទៅអនាគត ។

សូមទ្រង់ព្រះមេត្តាប្រោស ! កាលពីឆ្នាំ ១.៥០០ មុននេះ ប្រទេសខ្មែរនឹងប្រទេសលង្កា បានចងមេត្រីភាពនឹងគ្នាយ៉ាងជិតស្និទ្ធ ។ អ្នកប្រាជ្ញខ្មែរ ក៏បានអញ្ជើញទៅលង្កា . អ្នកប្រាជ្ញលង្កាក៏បានអញ្ជើញមកស្រុកខ្មែរ ដើម្បីបំពេញកិច្ចសាសនារៀងខ្លួន ។ ទូលព្រះបង្គំជាខ្ញុំស្តាយជាទីបំផុត បំពោះមេត្រីភាពនៃប្រទេសទាំងពីរនេះ ដែលឃ្លាតចេញពីគ្នា ចំនួន ២០០ ឆ្នាំមកហើយ ព្រោះហេតុតែប្រទេសទាំងពីរ ធ្លាក់ចុះទៅក្នុងអាណាព្យាបាលនៃប្រទេសដទៃ ។ ក្នុងសម័យនេះប្រទេសទាំងពីរនេះ មិនទាន់ជិតដិតនឹងគ្នាដូចពីមុនឡើងវិញទេ ។

ពិធីសម្ពោធដ៏ឧឡារិកនេះ ជារូបនិម្មិត ១ នៃមេត្រីភាពនោះ ដែលនឹងចាប់ផ្តើមមានឡើងវិញជាថ្មី តាំងពីឥឡូវនេះទៅ ហើយជាហេតុដែលនាំឲ្យទូលព្រះបង្គំជាខ្ញុំ មានសេចក្តីចាប់អារម្មណ៍មិនភ្លេចក្នុងដំណើរបេសកកម្មនេះផង ។

ម្យ៉ាងទៀត ក្នុងពេលដែលប្រទេសនានា កំពុងតែត្រូវភ្លើងសង្គ្រាមរាតត្បាតនេះ ប្រទេសកម្ពុជាមានអសន្តិសុខតែមួយក្នុង ១០ ប៉ុណ្ណោះទេ ដោយព្រះបរិញ្ញាណនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាអគ្គសាសនូបត្ថម្ភយ៉ាងប្រសើរ ។ នេះទុកជាភ័ព្វយ៉ាងប្រសើរនៃប្រទេសកម្ពុជាដែលនាំឲ្យព្រះបង្គំជាខ្ញុំ មានសេចក្តីរីករាយជាមួយផង ។

ថ្ងៃមង្គលនេះ មិនមែនគ្រាន់តែជានក្ខត្តឫក្ស សំរាប់ការធ្វើងខឿន ព្រះពោធិព្រឹក្សតែម្យ៉ាងឡើយ គឺជាថ្ងៃដែលប្រទេសកាន់ពុទ្ធសាសនា ទាំង ៦៤ កុងលោក បានចាប់ផ្ដើមប្រើទង់សាសនា ហើយនឹងធ្វើសាខ បូជា កុងថ្ងៃជាមួយគ្នា ដើម្បីទុកជាកស្តុតាងនៃសាមគ្គីទៅអនាគត ។

កុងអវសាននៃសេចក្ដីនេះ ទូលព្រះបង្គំជាខ្ញុំមានចិត្តសោមនស្សជាទីបំផុត ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលបានទ្រង់ព្រះរាជទានព្រះរាជវរោកាសជាកិត្តិយស ដល់សុន្ទរកថារបស់ទូលព្រះបង្គំជាខ្ញុំនេះផង សូមសំដែងអំណរគុណចំពោះលោក-អ្នកសប្បុរសទាំងឡាយ ដែលបានអញ្ជើញមកជួបជុំយ៉ាងកុះករកុងទីនេះផង ។

បន្ទាប់ពីសុន្ទរកថានេះមក, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានស្ដេចយាងលើបុប្ផាសនៈ ទៅកាន់ព្រះពោធិព្រឹក្សធំទង់ដែលមានរុំគល់ដោយសំពត់លឿង ហើយប្រដាប់ដោយទង់សាសនានៅជុំវិញជាកិត្តិយស ។ នៅលើខឿនមានដកល់ទឹកអប់កុងផ្តិលប្រាក់ធំៗ នៅគ្រប់ទិសទាំង ៨ ។ ព្រះរាជាទ្រង់ប្រទក្សិណដើមពោធិ៍ ដោយមានលោកឯកឧត្តមនាយករដ្ឋមន្ត្រី, ឯ.ឧ. សម - ញាណ, សម្ដេចសង្ឃនាយកជួន - ណាត, ព្រះតេជព្រះគុណព្រះពោធិវង្សហួត - តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់, ព្រះភិក្ខុប៉ាង-ខាត់ នឹងព្រះគ្រូសំសត្ថា ប៉ុណ្ណ-សម្ពាជ ដែលជាសាក្សីពេជ្រញាណនៃពិធីនេះ ព្រមទាំងលោកម៉ាលាល់ៈសេរេរៈតាម

ហែជាមួយផង ។ ព្រះករុណាទ្រង់ទទួលកួងផ្កាដែលនារីពីរនាក់ថ្វាយនៅត្រង់អាសនៈដែលដាំកល់ពីខាងកើតដើមពោធិ៍ ហើយទ្រង់បូជាចំពោះព្រះពោធិ៍ ព្រមទាំងយកសុគន្ធវារីប្រោះព្រំផង ។

តពីនោះមកទៀត ឯកឧត្តម អ៊ុំ-ឈាងស៊ុន លោកមហាបណ្ឌិត ម៉ាឡាឡាសេកេរៈ, ឯកឧត្តមសម-ញាណ បានទទួលកិត្តិយសប្រោះព្រំជាលំដាប់គ្នា ស្រេចហើយទើបពុទ្ធបរិសទ្យ នាំគ្នាទៅធ្វើនមស្សការដោយដុំដិត ។

កងឱកាសដែលព្រះរាជាប្រទានសុគន្ធវារីនេះ មានព្រះសង្ឃ ៨០ អង្គ ដែលតម្រូវតាមព្រះជន្មនៃព្រះសម្មាសម្ពុទ្ធ ស្វាធ្យាយធម៌ជយន្តោប្រសិទ្ធិពរជោគជ័យមង្គលដល់ដើមពោធិព្រឹក្ស ។ លុះស្រេចកិច្ចនេះហើយ, ព្រះរាជាស្តេចយាងទៅកាន់ព្រះរាជនិវេសន៍វិញ ។

## សន្និសិទលោកម៉ាឡាឡាសេកេរៈ ធ្វើនៅសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

កាលពីថ្ងៃទី ២០ ខែឧសភា គ. ស. ១៩៥១ នេះ ក្រោយដែលបានធ្វើពិធីសម្ពោធព្រះពោធិព្រឹក្សរួច លោកម៉ាឡាឡាសេកេរៈ បានធ្វើសន្និសិទមួយ អំពីរឿងប្រជុំមហាសន្និបាតពុទ្ធសាសនានៅលង្កាទ្វីបតាមសេចក្តីអញ្ជើញនៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ។ កងបរិវេណសាលាបាលីជាន់ខ្ពស់ទាំងមូល មានព្រះសង្ឃនិងគ្រហស្ថ ទាំង

ស្រីទាំងប្រុស ប្រហែល ៧.០០០ នាក់ បានស្ដាប់សន្និសីទនេះ ដោយសេចក្ដីរីករាយ ។

មហាបណ្ឌិតនេះ បានថ្លែងបាឋកថាតគ្រាន់ជាភាសាអង់គ្លេស ដោយមានលោក ក្រុមង៉ុ-ប៉ាន់ ជាអ្នកបកប្រែជាភាសាខ្មែរ ។ បាឋកថានោះមានសេចក្ដីសង្ខេប ដូចតទៅនេះ :–

បងប្អូនពុទ្ធសាសនាទាំងឡាយ !

ខ្ញុំត្រេកអរណាស់ ចំពោះកិច្ចដែលអស់លោក-អ្នកបានជូនកិត្តិយសដ៏ខ្ពង់ខ្ពស់ដល់ខ្ញុំ ដើម្បីនឹងឲ្យរ៉ាយរ៉ាប់អំពីបុព្វហេតុនៃការប្រជុំពុទ្ធសាសនានៅលង្កាទ្វីប ដែលបានធ្វើកាលពីឆ្នាំទៅមិញ ។ ក្នុងទីប្រជុំនោះប្រទេសខ្មែរក៏ជាសមាជិកផងដែរ ។

ខ្ញុំសូមជំរាបថា: ការប្រជុំនេះមានបំណងនឹងធ្វើតាំងពីឆ្នាំ គ.ស. ១៩៤៩ មកម៉្លេះ ដោយបានគ្រោងសេចក្ដីអញ្ជើញប្រទេសកាន់ពុទ្ធសាសនាទាំងអស់ ទៅប្រជុំនៅលង្កាទ្វីប ។ តែកិច្ចការនេះ បានឡាយពេលដរាបមកដល់ខែឧសភាឆ្នាំ គ. ស. ១៩៥០ ទើបសម្រេច ព្រោះមានឧបសគ្គជាច្រើនយ៉ាង ។ កាលពីឆ្នាំទៅបានជាមិនបានប្រជុំសម្រេចនៅខាងដើមនៃខែឧសភា ព្រោះអាកាសនៅលង្កាទ្វីបកំពុងក្ដៅហែង ជាពេលដែលមិនអាចនឹងញុំាងសេចក្ដីរីករាយឲ្យកើតមានដល់ទីប្រជុំបាន ។ ទាល់តែដល់មកថ្ងៃទី ២៥ ឧសភា ឆ្នាំ ១៩៥០ ជាសម័យដែលមាន

ធម្មជាតិទាំងពួងស្រស់ប្រិមប្រិយ ដោយសារអាកាសត្រជាក់នៃរដូវភ្លៀង ហើយដែលមានត្រយ៉ឈើនិងផ្កាឈើ ទើបនឹងពន្លកលេចឡើង ជាហេតុឲ្យកើតមនោរម្យដល់អ្នកដំណើរទាំងនោះ ។ គណៈកម្មការក៏បានណាត់យកពេលនេះជាឱកាសសន្និបាតធំ ។ មិនមែនគ្រាន់តែត្រូវយកអាកាសត្រជាក់ដើម្បីឲ្យស្រួលដល់ភ្ញៀវបរទេសប៉ុណ្ណោះទេ គឺបានទាំងត្រូវយកថ្ងៃដែលព្រះមហាមហិន្ទត្ថេរ នាំព្រះពុទ្ធសាសនាទៅប្រតិស្ឋាននៅលង្កាទ្វីប ដែលជាថ្ងៃសំខាន់បំផុតក្នុងប្រវត្តិសាស្ត្រផង ។

ម្យ៉ាងទៀត ខែឧសភា និងខែមិថុនានេះ ជាខែដែលមានបុណ្យធំមួយ ហៅថា "ជយន្តី" គឺបុណ្យវិសាខបូជា ដែលអាចនឹងឲ្យអ្នកតំណាងប្រទេសកាន់ពុទ្ធសាសនាទាំងប៉ុន្មាន មានឱកាសបានធ្វើក្នុងទីជាមួយគ្នាផង ដែលជាបឋមកិច្ចក្នុងការរួបរួមថ្ងៃធ្វើវិសាខបូជាឲ្យបានត្រូវគ្នា ព្រោះកាលពីមុននេះ ប្រទេសប៉ែកខាងមហាយាន គេបានធ្វើមុនពួកហីនយានមួយអាទិត្យ ។

នៅលង្កាទ្វីប បុណ្យវិសាខបូជានេះ គេបានធ្វើជាឧឡារិកណាស់ ។ អ្នករាជការឈប់ប្រកបកិច្ចការក្នុងមុខងាររបស់ខ្លួន ។ ក្នុងថ្ងៃបុណ្យនេះ គ្មានវត្តណាមួយ ឬគេហដ្ឋានណាមួយដែលមិនធ្វើពិធីនេះទេ ។ ពេលយប់ គេតែងភ្លើងយ៉ាងរន្ទាលច្រាលឆ្អៅនៅតាមវត្ត តាមគ្រឹះស្ថានរាជការ និងតាមគេហដ្ឋានផ្សេងៗ ព្រមទាំងមានការដង្ហែព្រះចង្ក្រមកែវ

ដែលមានក្បួនដ៏វែងយ៉ាងច្រើន ក្នុងពេលយប់នោះទៀតផង ។ ចំណែកព្រះពោធិព្រឹក្សនោះសោត ក៏គេតាក់តែងសក្ការៈយ៉ាងខ្ពង់ខ្ពស់បំផុត ។ មិនតែប៉ុណ្ណោះទៀយ ពួកគ្រហស្ថតែងនាំគ្នាផ្ដើមបអាហារយកទៅដាក់ទានដល់អ្នកកំសត់ទុគ៌ត ក្នុងពេលយប់នោះនឹងពេលព្រឹកឡើង ។

អំពីការឈប់សំរាកវិញ, ពិធីបុណ្យដ៏សំខាន់នេះ មិនមែនបើកឱកាសឲ្យតែអ្នកពជការប៉ុណ្ណោះទេ គឺត្រូវបានឈប់សំរាកការងារទាំងបណ្ដាក្រសួង ទាំងកម្មករ ទាំងសត្វពាហនៈ ទាំងអ្នកជាប់ទុក្ខទោស ។

ក្នុងពេលផ្ដើមមហាសន្និបាតនោះ មាន ៣២ ប្រទេសបានទៅប្រជុំ ដែលមានអ្នកតំណាងទាំងអស់ ១៣២ នាក់ គឺភូមា, ចិន, ទីបេត៍, ម៉ុងគោលី, ជប៉ុន, អូស្ត្រាលី, ភូឃាន, លង្កា, មាឡេហ្ស៊ី (សិង្ហបុរីនឹងពិណាំង), នេប៉ាល់, កម្ពុជា, ថៃ, វៀតណាម, ប៉ាគិស្ថាន, ឥណ្ឌា, ស៊ុកគិម, ហាវ៉ៃ, អស្ស៊ាំ, អាហ្វ្រិក, អាមេរិក ហើយនឹងប្រទេសប៉ែកខាងអឺរ៉ុប គឺអង់គ្លេស, បារាំង, អាលឡឺម៉ង់, ស្វីស, ណរវែស, ឆេកូស្លូវ៉ាគី, ដាណឺម៉ាក, ។ ល ។ មានតែប្រទេសមួយទេ ដែលមិនបានមកប្រជុំ គឺប្រទេសរុស្ស៊ី ។ ក្នុងចំនួនប្រទេសទាំងនេះ ប្រទេសខ្មែរមានអ្នកតំណាង៥រូបគឺ សម្ដេចព្រះមហាសុមេធាធិបតី ជួន - ណាត, ព្រះគ្រូសំសត្ថា ប៉ុណ្ណ - សម្ភារៈ, ឯកឧត្ដមប្រាក់ - សារិន នឹងឥស្សរជន ២ នាក់ទៀត ។

(មានត)